អត្ថបទស្រាវជ្រាវ

វ៉ុល២, លេខ៣, ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០

# កូវីដ១៩៖ ផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច

ជា មុយគីម*

អ្វីដែលចាប់ផ្តើមពីជំងឺការរាគត្បាតក្នុងស្រុកនៅតំបន់មួយក្នុងទីក្រុងវូហាន ខេត្តហ៊ូប៉ីនៃប្រទេសចិន បានក្លាយជាជំងឺសកលមួយធ្វើឱ្យពិភពលោកពោរពេញដោយភាពស្លន់ស្លោ និងភ័យខ្លាច។ បច្ចុប្បន្ន វីរុសនេះ បានប៉ះពាល់ដល់ប្រទេសចំនួន ២០៤ ប្រទេស និងតំបន់ ដែលបានឆ្លងដល់មនុស្ស ១.០៤១.១១៩ នាក់ និងធ្វើឱ្យមនុស្ស ៥៥.២០៣ នាក់ បាត់បង់ជីវិត[1]។ ក្នុងអំឡុងពេល ៣ខែ ចាប់តាំងពីការផ្ទុះឡើងនៃជំងឺនេះនៅចុងឆ្នាំ ២០១៩ ប្រទេសចិនបានឈរនៅលំដាប់កំពូលនៃបញ្ជីចំនួនអ្នកឆ្លង និងចំនួនអ្នកស្លាប់លើពិភពលោក រហូតមកដល់ថ្ងៃទី២៧ ខែមីនា ដែលសហរដ្ឋអាមេរិកបានជំនួសតំណែងនេះ ហើយទីក្រុងញូវយ៉កបានក្លាយជា ចំណុចកណ្តាលនៃជំងឺរាតត្បាត។ ប្រទេសអ៊ីតាលី ឈរនៅលំដាប់ទី២ ក្នុងបញ្ជីហើយបន្ទាប់មកគឺប្រទេសចិន អេស្ប៉ាញ និងអាល្លឺម៉ង់ តាមលំដាប់នៃចំនួនករណីអ្នកដែលបានឆ្លងជំងឺ។ ដោយទទួលស្គាល់ភាពធ្ងន់ធ្ងរនៃវីរុសកូរ៉ូណាថ្មីនេះ អង្គការសុខភាពពិភពលោកនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ បានប្រកាសជាផ្លូវការថាជំងឺនេះ គឺជាជំងឺរាតត្បាតសកល ដែលមានន័យថា វាមានផលប៉ះពាល់ទូទាំងពិភពលោក ក្រោយពីបានប្រកាសភាពអាសន្នលើសុខភាពសាធារណៈអន្តរជាតិកាលពីថ្ងៃទី៣០ ខែមករា កន្លងទៅ។ វីរុសថ្មីនេះត្រូវបានគេរកឃើញ និងរាយការណ៍ថាជាជំងឺមួយដែលត្រូវបានចម្លងពីសត្វទៅមនុស្សដោយមានប្រភពមកពីផ្សារអាហារសមុទ្រនៅទីក្រុងវូហាន ដែលសត្វព្រៃ ដូចជាទន្សាយ ប្រចៀវ និងពស់ ត្រូវបានលក់សេរី និងខុសច្បាប់។ គេជឿថាក្រុមមនុស្សដំបូងដែលឆ្លងវីរុសនេះ គឺក្រុមអ្នកលក់នៅផ្សារអាហារសមុទ្រវូហាន ដែលមានការទាក់ទងផ្ទាល់ជាមួយសត្វព្រៃទាំងនោះ។ យោងតាមការសិក្សារបស់អ្នកជំនាញខាងវីរុសសាស្ត្រនៅវិទ្យាស្ថានវូហានសម្រាប់វីរុសសាស្ត្រ ៩៦ ភាគរយនៃហ្សែនរបស់វីរុសកូរ៉ូណា ដែលត្រូវបានរកឃើញនៅក្នុងមនុស្ស មានភាពដូចគ្នាទៅនឹងហ្សែនវីរុសកូរ៉ូណាដែលមាននៅក្នុងសត្វប្រចៀវ (Reynolds, 2020)។ ក្រោយមក គេបានរកឃើញថា វីរុសនេះក៏អាចចម្លងពីមនុស្សទៅមនុស្សផងដែរ បន្ទាប់ពីបុគ្គលិកពេទ្យដែលបានផ្តល់ការព្យាបាលដល់អ្នកឆ្លងវីរុសនេះ បានឆ្លងពីអ្នកជំងឺ។ នោះហើយ ជាពេលដែលការឆ្លងពីមនុស្សទៅមនុស្ស បានចាប់ផ្តើមកើនឡើងក្នុងអត្រាដែលគួរឱ្យព្រួយបារម្ភរហូតដល់បច្ចុប្បន្ន។ បន្ទាប់ពីធ្វើការឥតឈប់ឈរដើម្បីកំណត់ពីមូលហេតុនៃជំងឺនេះ អង្គការសុខភាពពិភពលោកបានដាក់ឈ្មោះវាជាផ្លូវការថា «កូវីដ១៩» ដែលជាពាក្យកាត់សម្រាប់ «ជំងឺវីរុសកូរ៉ូណា២០១៩»។ រហូតមកដល់ពេលនេះ គេបានរកឃើញថាជំងឺកូវីដ១៩ កើតចេញពីវីរុសមួយឈ្មោះថា «Sars-CoV-2» ដែលស្ថិតនៅក្នុងក្រុមគ្រួសារវីរុសដូចគ្នា

[1] តួលេខនេះត្រូវបានធ្វើបច្ចុប្បន្នភាពត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ម៉ោង ១៤:៤៩ GMT ដោយគេហទំព័រ Worldometer។

***ជា មុយគីម** គឺជាអ្នកសម្របសម្រួលផ្នែកស្រាវជ្រាវ និងបោះពុម្ពផ្សាយនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

នឹងជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ ( SARS - Severe Acute Respiratory Syndrome ) ដែលត្រូវបានរកឃើញដំបូងនៅក្នុងប្រទេសចិន ដូចគ្នានៅឆ្នាំ២០០២ ( Reynolds, 2020 )។ ខណៈពេលដែលមូលហេតុពិតប្រាកដនៃការផ្ទុះឡើងនៃជំងឺ មិនទាន់ត្រូវបានគេដឹងនៅឡើយ ជំងឺកូវីដ១៩ បានបង្ហាញការកើនឡើងយ៉ាងឆាប់រហ័ស និងគួរឱ្យព្រួយបារម្ភនៅក្នុងប្រទេស និងតំបន់ជាង២០០ និងមានផលប៉ះពាល់ឆ្លងប្រទេស។ ការផ្ទុះឡើងនៃជំងឺនេះកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស ដែលបណ្តាលឱ្យផ្នែកខ្លះនៃអត្ថបទនេះអាចនឹងលែងត្រឹមត្រូវ ជាពិសេសចំនួនករណីឆ្លង និងចំនួនអ្នកស្លាប់ ព្រមទាំងផលប៉ះពាល់ជាក់ស្តែង ដែលមានទៅលើសេដ្ឋកិច្ចពិភពលោក និងតំបន់។ អត្ថបទនេះ នឹងពិភាក្សាពីឥទ្ធិពលរបស់បញ្ហាសន្តិសុខមិនមែនប្រពៃណី ដូចជាជំងឺកូវីដ១៩ ទៅលើសន្តិសុខរបស់ប្រទេស ប្រជាជន ទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ និងដំណើរការនៃសេដ្ឋកិច្ចពិភពលោក និងតំបន់ ក៏ដូចជាប្រទេសនានាដែលរងផលប៉ះពាល់។

## ❖ ផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចដោយជំងឺកូវីដ១៩

បច្ចុប្បន្ន ជំងឺកូវីដ-១៩ កំពុងជះឥទ្ធិពលទៅលើគ្រប់ផ្នែកទាំងអស់។ មេដឹកនាំនៃក្រុមសេដ្ឋកិច្ចរីកចម្រើន ដែលហៅកាត់ថា «G7» បានហៅជំងឺរាតត្បាតនេះថាជា "សោកនាដកម្មរបស់មនុស្ស និងវិបត្តិសុខភាពពិភពលោក" (White House, 2020)។ គេមិនអាចប្រកែកបានទេដែលថា ជំងឺកូវីដ១៩ ឥឡូវនេះកំពុងត្រួតត្រាទាំងស្រុងលើបញ្ហាទាំងឡាយលើពិភពលោក និងអាទិភាពដទៃទៀត។ គិតត្រឹមថ្ងៃទី១៦ ខែមីនា មានប្រទេសចំនួន១២៥ បានដាក់កម្រិតលើការធ្វើដំណើរទាំងផ្នែកខ្លះ ឬទាំងស្រុងលើអ្នកដំណើរដែលមកពីក្រៅប្រទេស ក្នុងគោលដៅបង្ការការរីករាលដាលនៃការនាំចូលករណីឆ្លង (Craven, Liu, Mysore & Wilson, 2020)។ សហគមន៍អន្តរជាតិ រួមមានអង្គការសុខភាពពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នអន្តរជាតិពាក់ព័ន្ធមួយចំនួន កំពុងតែបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ឱ្យស្របតាមការផ្លាស់ប្តូរនៃស្ថានភាពរបស់ជំងឺនេះ។ អង្គការសហប្រជាជាតិ បានរៀបចំកញ្ចប់ថវិកាចំនួន ២ ពាន់លានដុល្លារអាមេរិក ដើម្បីជួយដល់ប្រទេសងាយរងគ្រោះ ក្នុងគោលដៅកាត់បន្ថយបន្ទុកដែលរដ្ឋាភិបាលនៅក្នុងប្រទេសទាំងនោះដែលកំពុងជួបប្រទះ និងដើម្បីចូលរួមក្នុងការប្រយុទ្ធប្រឆាំងជាសកលនឹងជំងឺកូវីដ១៩ (Rowling, 2020)។ ដូចគ្នានេះដែរ អង្គការសហប្រជាជាតិ ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និង G20 បានជំរុញឱ្យប្រទេសអភិវឌ្ឍន៍ផ្តល់ជំនួយ តាមរយៈការបង្កើននូវមូលនិធិបន្ថែមជួយផ្គត់ផ្គង់ដល់ប្រទេសក្រីក្រ និងប្រទេសអភិវឌ្ឍន៍តិចតួចដើម្បីអាចឆ្លងកាត់វិបត្តិសកលនេះ។ ប្រធានផ្នែកមនុស្សធម៌នៃអង្គការសហប្រជាជាតិបានលើកឡើងថា៖ 'គ្មាននរណាម្នាក់អាចមានសុវត្ថិភាពឡើយ រហូតទាល់តែមនុស្សគ្រប់គ្នាមានសុវត្ថិភាព' (Rowling, 2020)។

ការអនុវត្តបទបញ្ជានៃការបិទប្រទេសទាំងស្រុង និងការបិទដោយផ្នែក នៅតំបន់ដែលរងការប៉ះពាល់ធ្ងន់ធ្ងរក្នុងប្រទេសមួយចំនួន ក្នុងគោលដៅទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ បានបង្ខំឱ្យអាជីវកម្ម និងកន្លែងជួបជុំសាធារណៈនានាត្រូវបានបិទទ្វារ។ ដោយសារការបិទប្រទេស និងការអនុវត្តគម្លាតសុវត្ថិភាព អាជីវកម្មគ្រប់ទំហំត្រូវរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីជំងឺកូវីដ១៩។ ការបិទទ្វារបណ្តោះអាសន្ននៃសាលារៀន ភោជនីយដ្ឋាន បៀរហ្គារឌិន និងទីសាធារណៈផ្សេងៗទៀត ក៏មានន័យថា ការផ្អាកការងារបណ្តោះអាសន្នរបស់បុគ្គលិក កម្មករ និយោជិត ប្រតិបត្តិការអាជីវកម្ម និងសកម្មភាពទាក់ទងនឹងសេដ្ឋកិច្ចផ្សេងទៀតដូចគ្នា។ គ្រួសារមួយចំនួនត្រូវប្រឈមនឹងការបាត់បង់ប្រាក់ចំណូលប្រចាំខែ

ដោយសារកន្លែងធ្វើការរបស់ពួកគេ ចាប់ផ្តើមផ្អាកប្រតិបត្តិការ ឬបានបិទទ្វារទាំងស្រុងតែម្តង។ ករណីនេះមានដូចជាហាងទំនិញតូចៗ រោងចក្រ ភោជនីយដ្ឋាន និងហាងទំនិញធំៗជាដើម។ អាជីវកម្មមួយចំនួន ក៏បានឃើញមានការធ្លាក់ចុះប្រាក់ចំណូលយ៉ាងគំហុក បើទោះបីជាពួកគេនៅតែបន្តបើកក៏ដោយក្តី ព្រោះមនុស្សកំពុងអនុវត្តគោលការណ៍គម្លាតសុវត្ថិភាព ឬនៅដាច់ដោយឡែកពីមនុស្សដទៃទៀតដោយការនៅផ្ទះ ដែលជាហេតុនាំឱ្យពួកគេកាត់បន្ថយការចំណាយយ៉ាងច្រើនទៅលើសម្ភារ ឬសេវាកម្មដែលមិនចាំបាច់។ ការបាត់បង់ប្រាក់ចំណូលជាបន្តបន្ទាប់នឹងប្រែទៅជាក្ស័យធនសម្រាប់អាជីវកម្ម ដែលនឹងបណ្តាលឱ្យចំនួននៃអ្នកគ្មានការងារធ្វើកាន់តែច្រើនឡើងៗ។ ការកើនឡើងនៃចំនួនអ្នកគ្មានការងារធ្វើ នឹងបង្ខំឱ្យប្រជាជនកាត់បន្ថយការចំណាយរបស់ខ្លួន ដែលនាំឱ្យមានការធ្លាក់ចុះប្រាក់ចំណូលពន្ធសម្រាប់រដ្ឋខណៈពេលដែលការចំណាយលើការផ្តត់ផ្គង់ដល់អ្នកបាត់បង់ការងារធ្វើកាន់តែកើនឡើង។ ទាក់ទងនឹងបញ្ហានេះ រដ្ឋាភិបាលនៃប្រទេសជាច្រើន បានរៀបចំកញ្ចប់ថវិកាដើម្បីជួយប្រជាជនឆ្លងកាត់ពេលវេលាដ៏លំបាកនេះ។ គួរឱ្យកត់សម្គាល់ផងដែរ ព្រឹទ្ធសភាសហរដ្ឋអាមេរិក នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ បានបោះឆ្នោតអនុម័តទៅលើកញ្ចប់ថវិកាគ្រាអាសន្ន ចំនួន ២០០ ម៉ឺនលានដុល្លារអាមេរិក ដើម្បីជួយដល់សេដ្ឋកិច្ច ហើយត្រូវបានចុះហត្ថលេខាដោយប្រធានាធិបតីនៅពីរថ្ងៃបន្ទាប់ពីការអនុម័តពីព្រឹទ្ធសភា (Pramuk, 2020)។ ស្រដៀងគ្នានេះដែរ រដ្ឋាភិបាលកាណាដាបានរៀបចំកញ្ចប់ថវិកាជំនួយចំនួន ៥២ ពាន់លានដុល្លារកាណាដា (ស្មើនឹង ៣៦,៦២ ពាន់លានដុល្លារអាមេរិក) កាលពីថ្ងៃទី២៥ ខែមីនា ដើម្បីទប់ទល់នឹងវិបត្តិជំងឺកូវីដ១៩ នៅក្នុងប្រទេស (Ljunggren, 2020)។ ប្រទេសជាច្រើនទៀត រួមមានចក្រភពអង់គ្លេស ប៉ូឡូញ ឥណ្ឌា ម៉ាឡេស៊ី ជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី និងសូម្បីតែកម្ពុជាដែលមានចំនួនអ្នកឆ្លងតែ១១៤ ករណី[2] ក្នុងចំណោមប្រទេសជាច្រើននៅទូទាំងពិភពលោក បានបំពេញតួនាទីរបស់ខ្លួនក្នុងការជួយសង្គ្រោះជីវិតប្រជាជន និងសេដ្ឋកិច្ចដោយប្រើប្រាស់កញ្ចប់ជំនួយសង្គ្រោះបន្ទាន់របស់ពួកគេរៀងៗខ្លួន។ កញ្ចប់ថវិកាជំនួយទាំងនេះ នឹងជួយឧបត្ថម្ភដល់អាជីវកម្មដែលកំពុងជួបប្រទះការខាតបង់ប្រាក់ចំណូល ហើយក៏ជួយជាថវិកាបណ្តោះអាសន្នដល់កម្មករ និងនិយោជិតដែលបានបាត់បង់ការងារអំឡុងពេលនៃការអនុវត្តគម្លាតសុវត្ថិភាពនេះ។ ប៉ុន្តែកញ្ចប់ថវិកាជំនួយនេះ គឺជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលកំពុងប្រយុទ្ធនឹងមេរោគនេះជាមួយថវិកាតិចតួចក្នុងដៃ ខណៈពេលពួកគេកំពុងព្យាយាមរក្សាស្ថិរភាពសេដ្ឋកិច្ចក្នុងពេលតែមួយ។

ភាពគ្មានការងារធ្វើ ក៏មានន័យថា សេដ្ឋកិច្ចកំពុងដំណើរការទាបជាងសមត្ថភាពរបស់ខ្លួន និងមិនមានប្រសិទ្ធផលឡើយ (Pettinger, n.d.)។ សកម្មភាពសេដ្ឋកិច្ចទាំងអស់នេះ សុទ្ធតែមានទំនាក់ទំនងគ្នា ហើយពឹងផ្អែកគ្នាទៅវិញទៅមក ដូចនេះនៅពេលដែលការដួលរលំនៃសកម្មភាពសេដ្ឋកិច្ចមួយ នឹងនាំឱ្យមានការប៉ះទង្គិចដល់សកម្មភាពមួយទៀត ដែលនៅចុងបញ្ចប់ សេដ្ឋកិច្ចទាំងមូលនឹងស្ថិតក្នុងសភាពនឹងទ្រឹង ហើយមិនមានដំណើរការទៅមុខ។ យោងតាមការលើកឡើងរបស់នាយកគ្រប់គ្រងមូលនិធិរូបិយវត្ថុអន្តរជាតិ IMF អ្នកស្រី Kristalina Georgieva បន្ទាប់ពីកិច្ចប្រជុំជាមួយរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងធនាគារកណ្តាលនៃសមាជិក G20 វិបត្តិសេដ្ឋកិច្ចពិភពលោកដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩ នឹងមានភាពអាក្រក់ជាងវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨-២០០៩ ទៅទៀត (KBS World Radio, 2020)។ យោងតាម

[2] បច្ចុប្បន្នភាពត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ យោងតាមសេចក្តីថ្លែងការណ៍ផ្លូវការរបស់ក្រសួងសុខាភិបាលកម្ពុជា។

សម្ដីអ្នកស្រី Georgieva សេដ្ឋកិច្ច និងទីផ្សារដែលទើបរីកចម្រើន នឹងទទួលរងផលប៉ះពាល់ខ្លាំងជាងគេក្នុងស្ថានភាពនេះ ខណៈប្រទេសមានសេដ្ឋកិច្ចធំ និងរីកចម្រើន នឹងអាចទប់ទល់នឹងវិបត្តិនេះបានប្រសើរជាង។ ទាក់ទងនឹងបញ្ហានេះ អ្នកស្រី Georgieva បានអះអាងថា ប្រទេសអភិវឌ្ឍន៍នឹងជួយប្រទេសដែលមានប្រាក់ចំណូលទាបក្នុងគ្រាលំបាកនេះ តាមរយៈការចូលរួមវិភាគទានថវិកាកាន់តែច្រើនជាងមុន ដើម្បីឱ្យគ្រប់គ្នាអាចឆ្លងកាត់វិបត្តិមួយនេះ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានគូសបញ្ជាក់តាមរយៈការរកឃើញរបស់ខ្លួនថា ជំងឺរាតត្បាតកូវីដ១៩ អាចធ្វើឱ្យសកលលោកខាតបង់ថវិកាចន្លោះពី ៧៧ពាន់លាន ទៅ ៣៤៧ពាន់លានដុល្លារអាមេរិក ស្មើនឹងការខាតបង់ប្រហែលពី ០,១ ទៅ ០,៤ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក (Himel, 2020)។ ការព្យាករសេដ្ឋកិច្ចដោយក្រុមអ្នកជំនាញ ក៏មានភាពប្រហាក់ប្រហែលគ្នា ដោយអះអាងថា វិធានចត្តាឡីស័កទ្រង់ទ្រាយធំ ការរឹតត្បិតការធ្វើដំណើរ និងវិធានការផ្សេងៗក្នុងន័យរក្សាគម្លាតសង្គម នឹងអាចនាំឱ្យមានការធ្លាក់ចុះនូវទម្លាប់នៃការចំណាយរបស់ប្រជាជន យ៉ាងហោចណាស់រហូតដល់ចុងត្រីមាសទី២ នៃឆ្នាំ២០២០ (Craven, Liu, Mysore & Wilson, 2020)។ ដរាបណាមិនមានវិធានការត្រឹមត្រូវក្នុងការទប់ស្កាត់ឥទ្ធិពលដែលជំងឺកូវីដ១៩ មានលើសេដ្ឋកិច្ចនោះទេ វានឹងប៉ះពាល់ដល់គ្រប់ស្រទាប់នៃសង្គម ហើយគ្មាននរណាម្នាក់អាចគេចផុតពីផលវិបាកឡើយ។ ផលប៉ះពាល់នៃជំងឺកូវីដ១៩ នឹងមានវត្តមាននៅគ្រប់ផ្នែកនៃពិភពលោក និងទៅលើមនុស្សគ្រប់រូប។

បើទោះបីជារបាយការណ៍សង្ខេបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចេញផ្សាយកាលពីដើមខែនេះ បានបញ្ជាក់ថា ពីរភាគបីនៃផលប៉ះពាល់សេដ្ឋកិច្ច នឹងត្រូវធ្លាក់លើប្រទេសចិនក៏ដោយ (Abiad et al., 2020) ផលប៉ះពាល់នឹងមានវិសាលភាពលើគ្រប់ផ្នែកនៃពិភពលោក ពីព្រោះចិន គឺជាចំណែកធំបំផុតក្នុងសង្វាក់ផ្គត់ផ្គង់ក្នុងពិភពលោក។ ការផ្ទុះឡើងនៃជំងឺកូវីដ១៩ ដែលមិនធ្លាប់មានពីមុននេះ បានបង្ហាញពីភាពងាយរងគ្រោះ និងភាពមិនបត់បែនរបស់ប្រទេស និងក្រុមហ៊ុនដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើដៃគូផ្គត់ផ្គង់តិចតួច។ ការរំខាននៃសង្វាក់ផ្គត់ផ្គង់ ក៏អាចបណ្ដាលឱ្យរោងចក្រ និងអាជីវកម្មបិទទ្វារជាបណ្ដោះអាសន្ន ព្រោះពួកគេមិនអាចបង្កើតផលិតផលរបស់ខ្លួនដើម្បីផ្គត់ផ្គង់ទីផ្សារបាន ហើយពេលខ្លះវាក៏អាចឈានទៅរកការក្ស័យធនផងដែរ។ ឧទាហរណ៍ ការស្ទង់មតិធ្វើឡើងដោយក្រុមហ៊ុនពិគ្រោះសង្វាក់ផ្គត់ផ្គង់របស់អាល្លឺម៉ង់ ឈ្មោះ Kloepfel Consulting បានបង្ហាញថា ៨១ ភាគរយនៃក្រុមហ៊ុនដែលមានមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់ទទួលបានការផ្គត់ផ្គង់ពីប្រទេសចិន (Tan, 2020)។ លើសពីនេះ វាត្រូវបានគេរាយការណ៍ថាមានការកើនឡើងប្រហែល ៤៤ ភាគរយ នៃការប្រើប្រាស់ឃ្លា "ប្រធានសក្តិ" ជាឃ្លានៅក្នុងកិច្ចសន្យាដែលត្រូវបានប្រើនៅពេលដែលកាលៈទេសៈ គេមិនអាចមើលឃើញទុកជាមុន ដែលរារាំងភាគីនៃកិច្ចសន្យាក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន (Tan, 2020)។ នេះគ្រាន់តែជាជុំទីមួយ នៃការរំខានដល់សង្វាក់ផ្គត់ផ្គង់ក្នុងពេលផ្ទុះឡើងនៃជំងឺកូវីដ១៩ ប៉ុណ្ណោះ។ ការរំខានជាបន្តបន្ទាប់ដល់សង្វាក់ផ្គត់ផ្គង់សកលគឺបណ្ដាលមកពីការកើនឡើងនៃករណីឆ្លងក្នុងប្រទេសកូរ៉េខាងត្បូង ហើយក្រោយមកត្រូវបានផ្លាស់ប្ដូរទៅភាគខាងលិចគឺទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិក ដែលឧស្សាហកម្មធំៗ ដូចជា យានយន្ត គ្រឿងអេឡិចត្រូនិក សម្ភារៈវេជ្ជសាស្ត្រ ឱសថ ទំនិញប្រើប្រាស់ និងផលិតផលផ្សេងទៀត បានក្លាយជាជនរងគ្រោះធ្ងន់ធ្ងរនៃជំងឺកូវីដ១៩។ ក្រុមហ៊ុនធំៗ មានដូចជា Apple, Microsoft, Nissan និងJCB ក៏បានត្អូញត្អែរអំពីការរំខានដែលបានប៉ះពាល់ដល់រោងចក្ររបស់ពួកគេ នៅក្នុងប្រទេសចិនផងដែរ (Brun, 2020)។ ដូចគ្នានេះដែរ ក្រុមហ៊ុនចំនួន

៩៣៨ ក្នុងចំណោមក្រុមហ៊ុនធំៗ Fortune ១.០០០ នៅទូទាំងសហរដ្ឋអាមេរិក បានបញ្ជាក់ថា អ្នកផ្គត់ផ្គង់ទី១ ឬទី២ របស់ពួកគេ បានរងផលប៉ះពាល់យ៉ាងខ្លាំងពីការផ្ទុះឡើងនៃមេរោគថ្មីនេះ (Brun, 2020)។ ផលប៉ះពាល់ពីការផ្ទុះឡើងនៃជំងឺនេះ មិនត្រឹមតែបង្កើតជាឧបសគ្គដល់ខ្សែសង្វាក់ផ្គត់ផ្គង់ប៉ុណ្ណោះទេ ប៉ុន្តែវាបានបញ្ឈប់ដំណើរការផលិតកម្មទាំងស្រុង ដែលបណ្តាលមកពីការរឹតត្បិតការធ្វើដំណើរ និងកង្វះកម្លាំងពលកម្ម ដោយសារតែវិធានការបិទទ្វារដែលត្រូវបានអនុវត្តដោយបណ្តាប្រទេសជាច្រើននៅលើពិភពលោកក្នុងពេលបច្ចុប្បន្ន។ ប្រសិនបើរោងចក្រ ឬសហគ្រាស ពុំមានភាពបត់បែនគ្រប់គ្រាន់ក្នុងការស្វែងរកអ្នកផ្គត់ផ្គង់ជំនួស ស្របពេលដែលមានការផ្លាស់ប្តូរភ្លាមៗនៃខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោកនោះទេ ពួកគេមុខជាជួបរលំមិនខាន។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺក្រុមហ៊ុនមួយចំនួនកំពុងមានក្តីសង្ឃឹមឡើងវិញ ដោយសារចិនចាប់ផ្តើមបើកសេដ្ឋកិច្ចឡើងវិញជាបណ្តើរៗ បន្ទាប់ពីការប្រយុទ្ធដ៏លំបាក និងដោយជោគជ័យប្រឆាំងនឹងជំងឺកូវីដ១៩ នៅក្នុងប្រទេសរបស់ខ្លួន។ យ៉ាងណាមិញ អ្នកជំនាញរំពឹងថា ស្ថានភាពអាចនឹងកាន់តែអាក្រក់ជាងមុន មុនពេលដែលវាអាចប្រសើរឡើងវិញ។ តម្លៃផលិតផលផ្គត់ផ្គង់ នឹងខ្ពស់ជាងមុន ដោយសារចំណាយលើការបន្ថែមម៉ោង និងការកើនឡើងនៃតម្លៃដឹកជញ្ជូន ព្រមទាំងការចំណាយផ្សេងៗ ដើម្បីទិញទំនិញ និងស្តុកទុក (PwC, n.d.)។ នៅក្នុងពិភពលោកដែលមានការផ្សារភ្ជាប់ និងពឹងផ្អែកគ្នាទៅវិញទៅមក ឬតាមអ្វីដែលអ្នកសិក្សាស្រាវជ្រាវ ជាទូហៅថា សកលភាវូបនីយកម្មនោះ ការផ្លាស់ប្តូរតូចមួយនៅកន្លែងមួយ ឬប្រទេសមួយ អាចមានផលប៉ះពាល់យ៉ាងធំធេងទៅលើកន្លែង និងប្រទេសដទៃទៀត ហើយដោយហេតុផលនេះ ប្រទេសនានានៅជុំវិញពិភពលោក គួរធ្វើសកម្មភាពរួមគ្នាក្នុងការខិតខំប្រឹងប្រែងដើម្បីគ្រប់គ្រងស្ថានភាពជំងឺកូវីដ១៩ ក្នុងពេលបច្ចុប្បន្ន ប្រសិនបើមិនអាចបញ្ចប់វាបានក្នុងរយៈពេលមួយដែលអាចព្យាករបាននោះទេ។

**ការកើនឡើងនៃចំណែករបស់ចិនក្នុងសកម្មភាពសេដ្ឋកិច្ចសកល**




**ប្រភព៖** Organization for Economic Cooperation and Development (OECD)

ឧស្សាហកម្មទេសចរណ៍ ជាឧស្សាហកម្មមួយក្នុងចំណោមឧស្សាហកម្ម ដែលរកប្រាក់ចំណូលបានច្រើនជាងគេសម្រាប់សេដ្ឋកិច្ច កំពុងទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីឥទ្ធិពលនៃជំងឺនេះ។ ខណៈពេលដែលបណ្តាប្រទេសនានា កំពុងបន្តបិទព្រំដែនរបស់ពួកគេ ឬដាក់កម្រិត និងរឹតត្បិតលើការធ្វើដំណើររបស់ប្រជាជន ក្រុមហ៊ុនអាកាសចរណ៍ជាច្រើន បាន

ផ្អាកជើងហោះហើររបស់ខ្លួន និងបន្ទប់នៃសណ្ឋាគារជាច្រើន ទំនេរមិនមានមនុស្សប្រើប្រាស់។ ផ្ទុយស្រឡះពីកាលពី ២ ឬ ៣ខែមុន ដែលតែងតែមានមនុស្សចេញចូលមិនស្រាកស្រាន្ត ដោយគ្មានពេលទំនេរ អាកាសយានដ្ឋានឥឡូវនេះ ប្រែជាមានសភាពស្ងប់ស្ងាត់។ ឧស្សាហកម្មទេសចរណ៍ ដែលមានចំនួនប្រមាណ១០ភាគរយ នៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក ពេលនេះកំពុងតែជិតដួលរលំ។ ការងាររហូតដល់ទៅ៥០លាន នៅក្នុងវិស័យទេសចរណ៍នៅទូទាំងពិភពលោក ឬស្មើនឹងការងារពី ១២ ទៅ ១៤ ភាគរយនៅទូទាំងពិភពលោក ឥឡូវនេះកំពុងប្រឈមនឹងការបាត់បង់ ដែលក្នុងនោះ មានចំនួន៣០លាននៃការងារទាំងអស់នេះ ស្ថិតនៅតំបន់អាស៊ី ចំនួន៧លាននៅអឺរ៉ុប និង ចំនួន៥លានកន្លែងនៅទ្វីបអាមេរិក ឯចំណែកនៅសល់ គឺនៅទ្វីបផ្សេងទៀត នេះបើយោងតាមរបាយការណ៍របស់ World Travel and Tourism Council (Faus, 2020)។ របាយការណ៍នេះ ក៏បង្ហាញផងដែរថា ការធ្លាក់ចុះនៃឧស្សាហកម្មទេសចរណ៍ ត្រូវការពេលយ៉ាងតិចណាស់ ១០ខែ ដើម្បីអាចត្រលប់មកស្ថានភាពធម្មតាវិញបាន។ ប៉ុន្តែការព្យាករនេះ ក៏អាស្រ័យលើថាតើជំងឺនេះនឹងនៅដល់ពេលណា។ បើជំងឺនេះនៅបន្តកាន់តែយូរ វានឹងមានផលប៉ះពាល់កាន់តែច្រើន ហើយក៏ត្រូវការពេលវេលាកាន់តែយូរដើម្បីឱ្យឧស្សាហកម្មទេសចរណ៍ត្រលប់ជាប្រសើរឡើងវិញ។ មុនពេលការផ្ទុះឡើងនៃជំងឺកូវីដ១៩ របាយការណ៍ព្យាករណ៍ឆ្នាំ២០២០ របស់អង្គការទេសចរណ៍ពិភពលោក (UNWTO) បានបង្ហាញថា វិស័យទេសចរណ៍នឹងមានការកើនឡើងពី៣ ទៅ ៤ ភាគរយ (World Tourism Organization [UNWTO], 2020)។ តែឥឡូវនេះ ដោយសារជំងឺកូវីដ១៩ គេបានកែសម្រួលកំណើនវិស័យទេសចរណ៍ទៅជាអវិជ្ជមានពី១ ទៅ ៣ ភាគរយដែលស្មើនឹងការខាតបង់ប្រមាណពី ៣០ ទៅ ៥០ ពាន់លានដុល្លារអាមេរិកនៅក្នុងចំណូលទេសចរណ៍អន្តរជាតិ (UNWTO, 2020)។ ដូចដែលបានរៀបរាប់ខាងលើ វាគឺជារឿងធម្មតា ដែលសកម្មភាពសេដ្ឋកិច្ចត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួត ហើយការដួលរលំវិស័យមួយនឹងជះឥទ្ធិពលជាបន្តបន្ទាប់ដល់សកម្មភាពសេដ្ឋកិច្ចដទៃទៀត។ ឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន លោក ដូណាល់ ត្រាំ បានជំរុញឱ្យអាជីវកម្មក្នុងប្រទេសបើកទ្វារឡើងវិញ នៅប៉ុន្មានសប្តាហ៍ខាងមុខនេះ ដោយលើកឡើងថា "[យើង] មិនអាចឱ្យការព្យាបាល (ដំណោះស្រាយ) មានភាពអាក្រក់ជាងបញ្ហានោះទេ" (Breuninger, 2020)។ ប៉ុន្តែ នៅប៉ុន្មានថ្ងៃបន្ទាប់ពីការប្រកាសរបស់ លោក ត្រាំ អំពីផែនការក្នុងការបើកសេដ្ឋកិច្ចអាមេរិកឡើងវិញ ករណីឆ្លងនៅអាមេរិកមានការកើនឡើងយ៉ាងលឿនពី ៣៥.០០០ ករណីនៅថ្ងៃទី២៣ ខែមីនា ទៅដល់ ២៤៥.៤៤២ ករណី[3] នៅថ្ងៃទី៣ ខែមេសា - ដែលជាការកើនឡើងជាង២១០.០០០ ករណី ក្នុងរយៈពេលប្រហែលមួយសប្តាហ៍តែប៉ុណ្ណោះ - ធ្វើឱ្យសហរដ្ឋអាមេរិកស្ថិតនៅលើគេក្នុងចំណោមប្រទេសដែលមានករណីឆ្លងជំងឺកូវីដ-១៩។ ការកើនឡើងនៃករណីឆ្លង ដែលមិនអាចគ្រប់គ្រងបាននេះ ធ្វើឱ្យផែនការស្តារសេដ្ឋកិច្ចរបស់លោក ត្រាំ ហាក់ដូចជាមិនអាចទៅរួច។ អ្វីដែលអាក្រក់ជាងនេះទៀត សហរដ្ឋអាមេរិក ជាប្រទេសមានសេដ្ឋកិច្ចធំជាងគេលើពិភពលោក និងជាប្រទេសដែលមានករណីឆ្លងកូវីដ១៩ ច្រើនជាងគេលើពិភពលោក បានចាប់ផ្តើមស្នើសុំជំនួយពីប្រទេសនានាជុំវិញពិភពលោក ក្នុងការផ្តល់ជំនួយជាសម្ភារគោល ដូចជាម៉ាស និងទឹកលាងដៃ ក៏ដូចជាសម្ភារសំខាន់ៗ ដូចជាបំពង់ខ្យល់ ដើម្បីប្រយុទ្ធនឹងជំងឺនេះ។

[3] បច្ចុប្បន្នភាពត្រឹមថ្ងៃទី២ ខែមេសា ឆ្នាំ២០២០ ម៉ោង ០៦:៥១ GMT ដោយគេហទំព័រ Worldometer។

## ព្យាករណ៍ឆ្នាំ២០២០ – ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ, ពិភពលោក

(ការផ្លាស់ប្តូរជាភាគរយ)




ប្រភព៖ The World Tourism Organization (UNWTO)

## ផែនទីពិភពលោកនៃប្រទេសកំពុងអនុវត្តការបិទប្រទេសអំឡុងជំងឺរាតត្បាតកូវីដ១៩

*ត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០




ប្រភព៖ Daily Mail

យ៉ាងណាក្ដី អាមេរិកមិនមែនជាប្រទេសតែមួយ ដែលទទួលរងនូវផលប៉ះពាល់នេះទេ។ ក្នុងចំណោមប្រទេសជាច្រើនដែលទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរពីជំងឺរាតត្បាតកូវីដ១៩ រួមទាំងប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោកមួយចំនួនផ្សេងទៀតដូចជា អ៊ីតាលី អេស្ប៉ាញ ចិន អាល្លឺម៉ង់ និងបារាំងជាដើម ក៏ឃើញថាមានការធ្លាក់ចុះជាប្រវត្តិសាស្រ្តនៃកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំដែរ ដោយសារវិធានការទប់ស្កាត់ និងបង្ការការរីករាលដាលរបស់វីរុសកូរ៉ូណា។ ប្រទេសជាច្រើនក្នុងទ្វីបអឺរ៉ុប កំពុងតែជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ដែលអាចខ្លាំងជាងអ្វីដែលពួកគេធ្លាប់ឆ្លងកាត់ អំឡុងពេលវិបត្តិហិរញ្ញវត្ថុសកលចន្លោះឆ្នាំ២០០៧ ដល់ ២០០៩ (Jackson, Weiss, Schwarzenberg, & Nelson, 2020)។ ស្របពេលជាមួយគ្នានេះ របាយការណ៍ពិសេសរបស់ក្រុមប្រឹក្សាផ្ដល់យោបល់ផ្នែកសេដ្ឋកិច្ចអាល្លឺម៉ង់ ដែលបានដាក់ជូនរដ្ឋាភិបាលអាល្លឺម៉ង់បានព្យាករថា ក្នុងស្ថានភាពអាក្រក់បំផុត សេដ្ឋកិច្ចអាល្លឺម៉ង់ អាចនឹងមានការធ្លាក់ចុះប្រមាណ ៥,៤ ភាគរយ។ ទោះបីជាទិន្នន័យនៃវិបត្តិនេះមើលទៅហាក់បីដូចជាមានភាពធ្ងន់ធ្ងរក៏ដោយក្ដី វិទ្យាស្ថានសេដ្ឋកិច្ចអាល្លឺម៉ង់(IW) បានព្យាករថានឹងមានការថយចុះយ៉ាងហោចណាស់ ១០ភាគរយនៃសេដ្ឋកិច្ចជាតិជាតិមូល (Deutsche Welle [DW], 2020)។ ចំណែកឯអ៊ីតាលី គេមើលឃើញថា កំណើនសេដ្ឋកិច្ចអ៊ីតាលីអាចនឹងដើរថយក្រោយ។ ភ្នាក់ងារពិគ្រោះផ្នែកស្រាវជ្រាវមួយឈ្មោះថា REF Ricerche ដែលមានទីតាំងនៅអ៊ីតាលី បានព្យាករថាជំងឺរាតត្បាតដែលបង្កដោយវីរុសកូរ៉ូណានេះ នឹងនាំឱ្យមានការធ្លាក់ចុះប្រមាណ ៨ ភាគរយ នៃផលិតផលក្នុងស្រុកសរុបរបស់អ៊ីតាលីនៅក្នុងឆមាសទី១ (Duddu, 2020) ខណៈសេដ្ឋកិច្ចរបស់អង់គ្លេស ត្រូវបានរំពឹកថា នឹងមានការធ្លាក់ចុះយ៉ាងគំហុកជាលើកដំបូង ចាប់តាំងពីឆ្នាំ១៩៨០ (Klayman, 2020)។ ដូចដែលបានលើកឡើងខាងលើ នៅក្នុងពិភពលោកមួយដែលមានទាំងសកលភាវូបនីយកម្ម និងការតភ្ជាប់គ្នាបែបនេះ ការជាប់គាំងភ្លាមៗនៃសកម្មភាពសេដ្ឋកិច្ច បូករួមទាំងការធ្លាក់ចុះមិនគ្រោងទុកជាមុននៃផលិតផលក្នុងស្រុកសរុបនៃបណ្ដាប្រទេសមហាអំណាចសេដ្ឋកិច្ច បានបង្កើតជាឥទ្ធិពលដូមីណូអវិជ្ជមាន និងផលប៉ះពាល់ជាច្រើនសាយភាយមកលើសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ករណីនៅប្រទេសអ៊ីរ៉ង់ គឺជាឧទាហរណ៍ជាក់ស្ដែង។ នៅសាធារណៈរដ្ឋអ៊ិស្លាមអ៊ីរ៉ង់ ដែលទទួលរងឥទ្ធិពលផ្ទួបគ្នារវាងទណ្ឌកម្មពីសហរដ្ឋអាមេរិកផង និងជំងឺកូវីដ-១៩ ផងនោះ បានរុញច្រានប្រទេសមួយនេះឱ្យធ្លាក់ទៅក្នុងស្ថានភាពវិនាសកម្មដ៏អាក្រក់មួយ។ ស្របពេលដែលរដ្ឋាភិបាលបានបញ្ជាឱ្យបញ្ឈប់អាជីវកម្មទាំងឡាយណាដែលមិនចាំបាច់ ហើយដាក់ចេញនូវវិធានការឱ្យប្រជាពលរដ្ឋនៅក្នុងផ្ទះ ប្រជាជនអ៊ីរ៉ង់ និងជំនួញជាច្រើននឹងមិនអាចទ្រាំទ្ររហូតដល់ពេលដែលជំងឺរាតត្បាតស្ថិតក្រោមការគ្រប់គ្រងបានទេ។ គេបានរាយការណ៍ថា ថ្នាក់ដឹកនាំអ៊ីរ៉ង់ លោក Hassan Rouhani បានស្នើសុំកម្ចីចំនួន ៥ ពាន់លានដុល្លារអាមេរិកពីមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីស្ដារសេដ្ឋកិច្ចឱ្យត្រលប់ទៅរកសភាពដើមវិញ (Vahdat, 2020)។

ការឱ្យប្រជាជននៅផ្ទះ និងបិទការធ្វើជំនួញ មិនត្រឹមតែប៉ះពាល់ដល់សេដ្ឋកិច្ចតែមួយមុខនោះទេ វាថែមទាំងបង្កគ្រោះថ្នាក់ដល់សុខមាលភាពសង្គម និងសុខភាពផ្លូវចិត្តស្ទើរគ្រប់ទីកន្លែងផងដែរ។ នៅអំឡុងពេលដែលបណ្ដាប្រទេសជាច្រើនកំពុងតែដាក់ចេញនូវវិធានការហាមឃាត់ការធ្វើដំណើរក្នុងរយៈពេលចន្លោះពី ២សប្ដាហ៍រហូតដល់២ខែ មនុស្សជាច្រើនកំពុងតែជួបប្រទះនូវអារម្មណ៍ធុញថប់។ ការបង្ខាំងនៅមួយកន្លែងមានផលប៉ះពាល់ដល់មនុស្សទាំងផ្លូវកាយ និងផ្លូវចិត្ត។ ការសិក្សារបស់ King's College London បានបង្ហាញថាការបង្ខាំងឱ្យនៅមួយកន្លែង អាចបង្កឱ្យមានការប៉ះទង្គិចផ្លូវចិត្ត ការភាន់ច្រលំ និងបង្កើតឱ្យមានកំហឹងក្នុងខ្លួន (Allmandou,

2020)។ ៩០ ភាគរយនៃភាពមិនប្រក្រតីទាំងនេះ ត្រូវបានរកឃើញថាមានទំនាក់ទំនងទៅនឹងជំងឺកូវីដ១៩។ ការសិក្សាដដែលនេះបានបញ្ជាក់បន្ថែមទៀតថា ការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នាក្នុងរយៈពេលវែង អាចនាំឱ្យមានចំណង់សេពជាតិអាល់កុលលើសកំណត់ និងរោគសញ្ញាជាច្រើនទៀត។ ការអះអាងនេះ ស្របទៅនឹងរបាយការណ៍មួយទៀត ដែលបានលើកឡើងថា នៅទីក្រុងជាំងចូវនៃខេត្តហ៊ូប៉ី មានការកើនឡើងករណីហិង្សាក្នុងគ្រួសាររហូតដល់បីដង បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន (Zhang, 2020)។ ករណីនេះ មិនត្រឹមតែកើតឡើងនៅប្រទេសកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះទេ សូម្បីតែប្រទេសជឿនលឿន ដូចជាបារាំង ក៏កំពុងជួបប្រទះការកើនឡើងនៃករណីអំពើហិង្សាក្នុងគ្រួសារដ៏គួរឱ្យបារម្ភដែរ។ យោងតាមទិន្នន័យរបស់ក្រសួងមហាផ្ទៃបារាំង អំពើហិង្សាក្នុងគ្រួសារនៅទូទាំងប្រទេសបានកើនឡើង ៣៦ ភាគរយ ចាប់តាំងពីការបិទការធ្វើដំណើរពីថ្ងៃទី១៧ ខែមីនាមក (Domestic Violence Cases Jump 30% during Lockdown in France, 2020)។ ផលលំបាកផ្នែកហិរញ្ញវត្ថុក្នុងអំឡុងពេលដែលមានស្ថានភាពតានតឹង ជំរុញឱ្យមានភាពដុនដាបនៃសុខភាពផ្លូវចិត្តរបស់ពួកគេថែមមួយកម្រិតទៀត។ មុនពេលការបិទការធ្វើដំណើរ និងការដាក់ឱ្យនៅដាច់ពីគ្នា ជំងឺកូវីដ១៩ បានជ្រៀតចូលទៅក្នុងសុខុមាលភាពផ្លូវចិត្តរបស់ប្រជាជនរួចទៅហើយ។ ការទិញដោយស្លន់ស្លោក្រោមឥទ្ធិពលជំងឺកូវីដ១៩ បានធ្វើឱ្យមនុស្ស ជាពិសេសមនុស្សចាស់ កាន់ងាយនឹងឆ្លងជំងឺនេះបន្ថែមទៀត ដោយសារការផ្គត់ផ្គង់ស្បៀងអាហារ និងរបស់ចាំបាច់ផ្សេងៗទៀត ដូចជា ម៉ាសការពារ និងទឹកលាងដៃ ត្រូវបានប្រមូលទិញស្ទើរតែអស់ពីស្តុកនៅកន្លែងមួយចំនួន។ ការទិញដោយស្លន់ស្លោបែបនេះ មិនគួរ និងមិនអាចបកស្រាយថាជា ការរៀបចំទប់ស្កាត់គ្រោះមហន្តរាយបានឡើយ។ វាជារឿងពីរខុសគ្នាទាំងស្រុង ហើយមានចំណុចខ្លះ ផ្ទុយគ្នាតែម្តង។ ការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយដ៏ត្រឹមត្រូវសម្រាប់ប្រជាជនគឺ ការស្តុកទុករបស់របរក្នុងចំនួនសមរម្យមួយទុកសម្រាប់ពេលមានគ្រោះមហន្តរាយ ដែលមើលមិនឃើញមុន ដូចជាទឹកជំនន់ ឬខ្យល់ព្យុះជាដើម។ ប៉ុន្តែក្នុងករណីនេះ មនុស្សជាច្រើន មិនដឹងច្បាស់ឡើយថា ពេលណាជំងឺរាតត្បាតនេះនឹងបញ្ចប់នោះទេ ដូច្នេះ អ្នកជំនាញចិត្តវិទ្យាបានពន្យល់ថា មនុស្សនាំគ្នាទិញទំនិញតាមដែលពួកគេអាចធ្វើបាន ព្រោះពួកគេគិតថា នេះជាអ្វីដែលពួកគេអាចធ្វើបានដើម្បីគ្រប់គ្រងស្ថានការណ៍ (Lufkin, 2020)។ អ្វីដែលធ្វើឱ្យមានភាពខុសគ្នារវាងការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ និងការទិញដោយភ័យស្លន់ស្លោអំឡុងពេលមានវិបត្តិ គឺនៅពេលដែលមានគ្រោះមហន្តរាយដូចជាទឹកជំនន់ និងខ្យល់ព្យុះកើតឡើង មនុស្សអាចមានតម្រុយខ្លះថា ពេលណាវានឹងបញ្ចប់ទៅវិញ តែការទិញដោយស្លន់ស្លោក្នុងស្ថានភាពអាសន្ននៃជំងឺកូវីដ១៩នេះវិញ មនុស្សមិនអាចដឹងថា តើពេលណាស្ថានភាពនឹងត្រឡប់ទៅរកភាពប្រក្រតីជាធម្មតាវិញ ដែលមនុស្សគ្រប់គ្នាអាចទិញអ្វីៗតាមចិត្តបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ អ្នកជំនាញម្នាក់ទៀតជឿថា ការទិញដោយស្លន់ស្លោនេះ បណ្តាលមកពីកង្វះទំនុកចិត្តទៅលើអាជ្ញាធរ រួមទាំងរដ្ឋាភិបាលក្នុងការដោះស្រាយវិបត្តិ (Lufkin, 2020)។ លោក Steven Taylor សាស្ត្រាចារ្យ និងជាអ្នកជំនាញចិត្តវិទ្យាផ្នែកវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យ British Columbia បានលើកឡើងថា ការចែករំលែករូបភាពនៃការទិញទំនិញច្រើនហួសលើបណ្តាញសង្គម នឹងជំរុញឱ្យអ្នកផ្សេងទៀតធ្វើដូចគ្នាដែរ។ គាត់បានបន្ថែមថា "ប្រសិនបើអ្នកផ្សេងទៀតនៅលើកប៉ាល់ទីតានិកកំពុងរត់រកទូកសង្គ្រោះ អ្នកនឹងរត់ទៅរកវាដែរ ដោយមិនខ្វល់ថាតើកប៉ាល់កំពុងលិច ឬអត់ទេនោះទេ" (Lufkin, 2020)។ ឥរិយាបថបែបនេះ នឹងនាំឱ្យមានការឡើងថ្លៃ និងកង្វះការផ្គត់ផ្គង់ជាក់ជាមិនខាន។

ការកើនឡើងជាគំហុកនៃតម្រូវការមិនបានរំពឹងទុក ដែលនាំឱ្យមានការប្រមូលទិញរហូតអស់ពីហាងនេះ អ្នកលក់បន្តតាម Amazon, eBay, Walmart និង Etsy ជាដើម ធ្វើការឡើងថ្លៃទៅលើមុខទំនិញមួយចំនួនដូចជា ទឹកលាងដៃ ម៉ាសសម្លៀកបំពាក់ការពារ និងផលិតផលវេជ្ជសាស្ត្រចាំបាច់ដទៃទៀតសម្រាប់ការរស់នៅប្រចាំថ្ងៃ។ ឧទាហរណ៍ ម៉ាសត្រូវបានលក់ក្នុងតម្លៃលើសធម្មតាស្ទើរតែ៦ដង (Palmer, 2020)។ បន្ថែមពីលើការលក់ម៉ាសក្នុងតម្លៃដ៏ថ្លៃលើសលប់នេះ អ្នកលក់មួយចំនួនបានបង្កើតផលិតផល ដែលពួកគេអះអាងថាអាចសម្លាប់វីរុសកូរ៉ូណាបាន ហើយខ្លះទៀតបានលក់ផលិតផលក្លែងក្លាយទៅឱ្យអតិថិជនដែលកំពុងភិតភ័យចំពោះជំងឺនេះ។ លើសពីនេះ ស្របពេលដែលកម្មករខំប្រឹងផលិតរបស់របរដើម្បីបំពេញតម្រូវការដែលខ្វះខាត គ្មាននរណាម្នាក់នឹងទិញទំនិញថ្មីទៀតឡើយ ព្រោះអ្នកដែលមានលទ្ធភាពទិញផលិតផលទាំងនោះ បានស្តុកវាទុករួចអស់ទៅហើយ ខណៈពេលប្រជាជនដែលរកចំណូលមួយថ្ងៃសម្រាប់តែរស់មួយថ្ងៃ មិនមានលទ្ធភាពទិញទំនិញចាំបាច់ទាំងនេះនោះទេ។ អ្នកជំនាញគម្រោងគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ លោក Daniel Stanton បានហៅវាថា «តម្រូវការផ្លេកបន្ទោរ» ព្រោះប្រជាជនដែលទិញច្រើន មិនបានបរិភោគ ឬមិនប្រើប្រាស់ទំនិញច្រើនជាងមុននោះទេ ហើយដោយសារហេតុផលនេះនៅពេលស្ថានការណ៍ប្រសើរឡើងវិញ គោលការណ៍នៃការផ្គត់ផ្គង់ និងតម្រូវការ នឹងមានភាពរអាក់រអួលម្តងទៀត ដោយសារការផលិតហួសកម្រិតនៅក្នុងរោងចក្រ។

នៅជ្រុងមួយផ្សេងទៀត ការទិញដោយស្លន់ស្លោនេះបានបង្ហាញឱ្យយើងឃើញពីគម្លាតយ៉ាងធំរវាងអ្នកមាន និងអ្នកក្រ។ គម្លាតនេះ គឺកាន់តែធំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជានៅអាហ្វ្រិកភាគខាងត្បូងជាដើម ដែលសូម្បីតែក្នុងស្ថានភាពធម្មតា ក៏ប្រជាជនជាទូទៅ មិនមានលទ្ធភាពទិញរបស់ដែលពួកគេត្រូវការបានដែរ (Lappeman, 2020) ដូច្នេះវាច្បាស់ថាពួកគាត់មិនអាចស្តុកទុករបស់ប្រើប្រាស់បានទេ នៅពេលមានវិបត្តិបែបនេះ ទាំងដែលពួកគាត់លែងមានប្រាក់ចំណូលដូចមុនទៀតនោះ។ ទោះបើករណីនេះ អាចជារឿងធម្មតានៅក្នុងប្រទេស ដូចជាអាហ្វ្រិកខាងត្បូង ប្រទេសជឿនលឿន ក៏មិនអាចគេចផុតពីភាពស្មុគស្មាញស្រដៀងគ្នានេះដែរ ភាពមិនស្មើគ្នា នឹងកើតឡើងនៅពេលដែលប្រជាជនចាប់ផ្តើមទិញរបស់ស្តុកទុក។ ធនាគារស្បៀងអាហារជាច្រើនបាន និងកំពុងបរិច្ចាគស្បៀង និងរបស់របរប្រើប្រាស់ដល់អ្នកដែលត្រូវការ ដូចជាជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោន ហើយនៅពេលនេះ សូម្បីអង្គការសប្បុរសធម៌ ក៏កំពុងប្រឈមនឹងកង្វះខាតការផ្គត់ផ្គង់ដូចគ្នា (BBC, 2020)។ ប្រជាជនដែលធ្លាប់តែទទួលបានការបរិច្ចាគទាំងនោះ ត្រូវដើរសុំជំនួយដើម្បីការរស់នៅរបស់ពួកគេបន្តទៀត។

ជាផ្នែកមួយនៃវិធានការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ យ៉ាងហោចណាស់ មានប្រទេសចំនួន១៩១ នៅជុំវិញពិភពលោក បានបញ្ជាឱ្យបិទស្ថាប័នអប់រំទាំងអស់ (Reuters, 2020)។ សិស្សនិស្សិតលើសពី ១,៣ ពាន់លាននាក់ ឬស្មើនឹង៨០ភាគរយនៃអ្នកកំពុងទទួលបានការអប់រំនៅទូទាំងពិភពលោកត្រូវបានប៉ះពាល់ដោយវិធានការនេះ។ ទោះបីជាថ្នាក់រៀនតាមអ៊ីនធឺណិតត្រូវបានផ្តល់ជូនជំនួសដោយថ្នាក់រៀនរូបវន្តក៏ដោយក្តី វាបានបង្ហាញពីវិសមភាពនៃសិទ្ធិទទួលបានការអប់រំ ព្រោះថាមិនមែនអ្នកសិក្សាទាំងអស់សុទ្ធតែមានកុំព្យូទ័រ ឬឧបករណ៍ឆ្លាតវៃដើម្បីចូលរួមក្នុងថ្នាក់រៀនតាមអ៊ីនធឺណិតនោះទេ។ នេះមិនទាន់រាប់បញ្ចូលទាំងការទទួលបានប្រព័ន្ធអ៊ីនធឺណិត និងបរិយាកាសដែលអំណោយផលដល់ការសិក្សារៀនសូត្រនៅក្រៅសាលាផង។ យន្តការបែបនេះ បានធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធទទួលបានការអប់រំរបស់អ្នកដែលមិនសូវមានលទ្ធភាព។

## ប្រទេស និងតំបន់ដែលបានបិទសាលារៀន និងសាកលវិទ្យាល័យ




*បច្ចុប្បន្នភាពត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

**ប្រភព៖** Reuters Graphics

មុនពេលការផ្ទុះឡើងនៃជំងឺនេះ មានសិស្សនិស្សិតប្រមាណ ២៥៨លាននាក់ នៅទូទាំងពិភពលោក បានបោះបង់ចោលការសិក្សាដោយសារភាពក្រីក្រ អភិបាលកិច្ចខ្សោយ និងស្ថានភាពរស់នៅមិនល្អ (Van Fleet, 2020)។ ការផ្ទុះឡើងនៃជំងឺនេះ បានធ្វើឱ្យប្រព័ន្ធអប់រំកាន់តែមានសភាពធ្ងន់ធ្ងរ ដែលធ្វើឱ្យអ្នកដែលបាត់បង់ឱកាសម្តងរួចមកហើយ កាន់តែគ្មានឱកាស។ ក្រៅពីនេះ នៅពេលដែលអ្វីៗវិលត្រឡប់មករកភាពប្រក្រតីវិញ រដ្ឋាភិបាល នឹងប្រឈមមុខជាមួយពេលវេលាដ៏លំបាក ក្នុងការសម្រេចចិត្តជ្រើសរើសប្រភេទកម្មវិធីសិក្សា និងអាទិភាពដែលរដ្ឋាភិបាលគួរផ្តល់ឱ្យសិស្សនិស្សិតជាមួយនឹងកញ្ចប់ថវិកាមានកំណត់ ដែលមួយផ្នែកខ្លះត្រូវបានប្រើប្រាស់ក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ រួចមកហើយ។ ការផ្លាស់ប្តូរបរិយាកាសរៀនសូត្រភ្លាមៗ ក៏នឹងជះឥទ្ធិពលដល់លទ្ធផល និងផលិតភាពនៃការរៀនសូត្ររបស់សិស្ស មួយកម្រិតផងដែរ ពីព្រោះមិនមែនសិស្សគ្រប់រូប សុទ្ធតែអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរថ្មីក្នុងរយៈពេលខ្លីបាននោះទេ ជាក់ស្តែងក្នុងករណីដែលរងផលប៉ះពាល់យ៉ាងខ្លាំង និងបន្ទាន់ដោយកូវីដ១៩ នេះ។ ចំពោះការរីករាលដាលនៃជំងឺកូវីដ១៩ នេះ ក្តីព្រួយបារម្ភខ្លាំងជាងគេនោះ គឺសុខភាព ការអប់រំ និងឥរិយាបថប្រជាជនឆ្លើយតបទៅនឹងជំងឺនេះ។ ចាប់តាំងពីមានការសាយភាយព័ត៌មានអំពីការផ្ទុះឡើងនៃជំងឺនេះកាលពីខែធ្នូ នៅឆ្នាំមុន ប្រជាជន បានចាប់ផ្តើមចាត់ទុក ជំងឺកូវីដ១៩ ជាជំងឺដ៏កាចសាហាវមួយ។ រឿងដែលកាន់តែអាក្រក់នោះ គឺមានការកើនឡើងនៃការរើសអើង និងការស្អប់ខ្ពើមជនជាតិចិនក្នុងន័យដោយឡែក និងជនជាតិអាស៊ីក្នុងន័យរួម។ ដោយសារការយល់ច្រឡំលើជំងឺមួយនេះ មនុស្សមួយចំនួនគិតខុសថាជនជាតិអាស៊ី គឺជាអ្នកចម្លងជំងឺនេះ។ ការយល់ច្រលំនេះ គួបផ្សំជាមួយពាក្យថា «វីរុសចិន» ដែលត្រូវបានប្រើនៅក្នុងសេចក្តី

ថ្លែងការណ៍ លោក ដូណាល់ ត្រាំ ប្រធានាធិបតីសហរដ្ឋអាមេរិក ដើម្បីពិពណ៌នាពីជំងឺកូវីដ១៩ (Al Jazeera, 2020) ដែលធ្វើឱ្យមានប្រតិកម្មពីមហាជនទៅលើការប្រើប្រាស់ពាក្យនេះ។ ក្រោយមក លោកប្រធានាធិបតី ត្រាំ បានកែប្រែការប្រើប្រាស់ពាក្យសម្ដីរបស់គាត់វិញ ហើយបាននិយាយថា លោកនឹងមិនបន្តប្រើប្រាស់ពាក្យនោះទៀតទេ។ ការលើកឡើងដ៏រើសអើងដែលលោក ត្រាំ ធ្លាប់ការពារពីពេលមុននេះ កើតឡើងក្រោយពេលអាមេរិក និងចិន បានចង្អុលគ្នាទៅវិញទៅមកដោយប្រើទ្រឹស្ដី Conspiracy ថាអ្នកម្ខាងទៀត បានបង្កើតវីរុសនេះឡើងរៀងៗខ្លួន។ ភាពចម្រូងចម្រាសនេះ ពិតជាបានបង្កឱ្យមានការភាន់ច្រលំចំពោះមនុស្ស ដែលមានការភ័យខ្លាចស្រាប់ និងជំរុញអារម្មណ៍ទើសទាល់របស់ពួកគេទៅលើប្រជាជនអាស៊ីឱ្យកាន់តែខ្លាំងឡើង។ អត្ថបទព័ត៌មាន និងរឿងរ៉ាវជាច្រើនបានចរាចរពាសពេញបណ្ដាញសង្គម ដែលនិយាយអំពីជនជាតិអាស៊ីមួយចំនួនដែលរស់នៅប្រទេសក្រៅ ត្រូវបានគេធ្វើបាបក្នុងរូបភាពផ្សេងៗ នៅពេលមានរោគរាតត្បាតនេះ រួមមាន ការវាយប្រហារតាមរយៈពាក្យសម្ដី រហូតដល់ការវាយដំលើរាងកាយ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាដើម។ ការស្អប់ខ្ពើមជាតិសាសន៍មួយមិនមានព្រំដែននោះទេ ហើយនឹងកាន់តែធ្ងន់ធ្ងរទៅ វៀរលែងតែព័ត៌មានសមស្របមួយទាក់ទងនឹងជំងឺនេះ ត្រូវបានផ្សព្វផ្សាយឱ្យសាធារណៈជនបានដឹងច្បាស់។ មិនត្រឹមតែប៉ុណ្ណោះ ការបែងចែកសង្គមបានធ្វើឱ្យមនុស្សបែកបាក់ និងឃ្លាតឆ្ងាយពីគ្នាទាំងមិនដឹងខ្លួន។

### ❖ ការឆ្លើយតបនានាជាសាកល និងនៅតាមតំបន់ ចំពោះជំងឺកូវីដ១៩

រហូតមកដល់បច្ចុប្បន្ននេះអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវនៅជុំវិញពិភពលោកកំពុងប្រណាំងប្រជែងជាមួយនឹងពេលវេលា ដើម្បីស្វែងរកការព្យាបាលជំងឺរាតត្បាត ដែលកំពុងតែផ្ដល់ក្ដីព្រួយបារម្ភជាសាកល និងធ្វើឱ្យខាតបង់ដល់ការរីកចម្រើន និងការអភិវឌ្ឍទូទាំងពិភពលោក។ វ៉ាក់សាំងដែលអាចធានាការព្យាបាលទាំងស្រុង អាចត្រូវការពេលវេលាច្រើនទៀត ដោយសារថាមូលហេតុពិតប្រាកដនៃវីរុសនេះមិនទាន់ត្រូវបានគេកំណត់អត្តសញ្ញាណនៅឡើយ។ ដំណាក់កាលដំបូងនៃការសាកល្បងក្នុងគ្លីនិកសម្រាប់វ៉ាក់សាំងការពារមេរោគកូរ៉ូណាប្រភេទថ្មីនេះ ត្រូវបានធ្វើឡើងនៅសហរដ្ឋអាមេរិកលើអ្នកស្ម័គ្រចិត្ត ៤៥ នាក់ ដែលមានអាយុខុសៗគ្នា ហើយពួកគេត្រូវបានតាមដានយ៉ាងជិតដល់ក្នុងរយៈពេល ៦ សប្ដាហ៍ (National Institute of Health [NIH], 2020)។ ក្រុមហ៊ុនបច្ចេកវិទ្យាជីវសាស្ត្រ និងវិទ្យាស្ថានស្រាវជ្រាវមួយចំនួនពីបណ្ដាប្រទេសជាច្រើន រួមទាំងចិន ជប៉ុន ចក្រភពអង់គ្លេស និងអាល្លឺម៉ង់ ក៏បានចូលរួមដើម្បីរកវិធីព្យាបាល និងវ៉ាក់សាំងនេះផងដែរ ប៉ុន្តែពួកគេនៅតែត្រូវការពេលវេលាសម្រាប់បញ្ជាក់ថា វាមានប្រសិទ្ធភាព និងមានសុវត្ថិភាពមុនពេលដាក់ឱ្យពលរដ្ឋប្រើប្រាស់។ ក្រៅពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ ប្រទេសនានានៅជុំវិញពិភពលោកក៏កំពុងអនុវត្ត និងត្រៀមវិធានការឆ្លើយតប ដើម្បីដោះស្រាយជាមួយនឹងការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺនេះ។ នេះ គឺជាការស្វែងយល់ពីរបៀបដែលបណ្ដាប្រទេសនៅជុំវិញពិភពលោក និងក្នុងតំបន់ ជាពិសេសអាស៊ានកំពុងតស៊ូជាមួយជំងឺកូវីដ១៩។ នៅសហរដ្ឋអាមេរិកដែលបច្ចុប្បន្នឈរនៅលំដាប់កំពូលនៃករណីឆ្លងជំងឺកូវីដ-១៩ ក្រុមការងារជំនាញផ្នែកជំងឺកូវីដ១៩ ដឹកនាំដោយលោក Mike Pence ត្រូវបានបង្កើតឡើងដើម្បីតាមដាន និងគ្រប់គ្រងឱ្យបានប្រសើរនូវគ្រប់ស្ថានភាពទាំងអស់ដែលទាក់ទងនឹងការរីករាលដាលនៃជំងឺនេះ។ ក្នុងនោះក៏មានផងដែរនូវបទបញ្ជា ដាក់កម្រិតលើការធ្វើដំណើរចូលមកពីប្រទេសចំនួន ២៦ នៅសហភាពអឺរ៉ុប ប្រទេសចិន និងបណ្ដាប្រទេសដទៃទៀត ដែលកំពុងស្ថិតក្នុងស្ថានភាពនៃការ

ឆ្លងកូវីដ១៩ ធ្ងន់ធ្ងរ។ លើសពីនេះ រដ្ឋចំនួន ៣២ នៅសហរដ្ឋអាមេរិក បានអនុវត្តបទបញ្ជាឱ្យស្នាក់នៅក្នុងផ្ទះ ដោយបង្ខាំងពលរដ្ឋអាមេរិកាំងប្រហែល ៨០ ភាគរយ នៃប្រជាជនសរុប (Secon & Woodward, 2020)។ ដោយឡែក រដ្ឋាភិបាលអ៊ីតាលី បានផ្លាស់ប្តូរនីតិវិធីដ៏តឹងរឹងបំផុតមួយ ពីការហាមឃាត់ការធ្វើដំណើរនៅតំបន់ ដែលរងគ្រោះខ្លាំងបំផុតនៅក្នុងប្រទេស ទៅជាការហាមឃាត់ដែលគ្របដណ្តប់ប្រទេសទាំងមូល រួមមានការរឹតត្បិតការធ្វើដំណើរ ហាមឃាត់ការជួបជុំ និងមានការដាក់បម្រាមគោចរជាដើម (Coronavirus: Italy Extends Emergency Measures Nationwide, 2020)។ សាលារៀន និងសាកលវិទ្យាល័យទូទាំងប្រទេសនៅតែបន្តបិទទ្វារ។ ដើម្បីទប់ស្កានភាពសេដ្ឋកិច្ចអំឡុងពេលផ្ទុះជំងឺនៅក្នុងប្រទេស នាយករដ្ឋមន្ត្រីអ៊ីតាលី បានប្រកាសនូវកញ្ចប់ជំនួយសង្គ្រោះបន្ទាន់ ចំនួន ២៨,៣ ពាន់លានដុល្លារអាមេរិក នៅដើមខែមីនា (Sirletti, Follain, & Rotondi, 2020)។ លើសពីនេះ រដ្ឋាភិបាល ក៏បានបញ្ជាឱ្យផ្អាករាល់ជើងហោះហើរពីប្រទេសចិន និងតៃវ៉ាន់ផងដែរ (Coronavirus: Travel Restrictions, Border Shutdowns by Country, 2020)។ ទោះយ៉ាងណាក្តី ប្រទេសអ៊ីតាលី មិនមែនជាប្រទេសនៅអឺរ៉ុបតែមួយទេដែលរងផលប៉ះពាល់នោះទេ ប្រទេសជាច្រើនទៀតនៅក្នុងតំបន់ ក៏មានវាសនាមិនខុសគ្នាដែរ។ ជាក់ស្តែង អេស្ប៉ាញ បានផ្អាករាល់ការធ្វើដំណើររបស់ភ្ញៀវទេសចរបរទេសទាំងអស់ ចូលប្រទេសរបស់ខ្លួន ដោយមិនរាប់បញ្ចូលប្រជាជនសហគមន៍អឺរ៉ុប ដែលធ្វើដំណើរតាមផ្លូវអាកាស និងសមុទ្រ ហើយការហាមឃាត់នេះ មានរយៈពេលមួយខែ ដោយចាប់ផ្តើមពីថ្ងៃទី២២ ខែមីនាមក (Castillo, 2020)។ ក្រៅពីនេះ អេស្ប៉ាញបច្ចុប្បន្ន ក៏កំពុងបិទប្រទេស ដោយមិនអនុញ្ញាតឱ្យប្រជាជនចេញក្រៅផ្ទះ លើកលែងចំពោះករណីចាំបាច់ បន្ទាប់ពីនាយករដ្ឋមន្ត្រីនៃប្រទេសនេះ បានប្រកាសពន្យារពេលវិធានការនេះ ពីថ្ងៃទី២៩ ខែមីនា ដល់ថ្ងៃទី១២ ខែមេសា (Coronavirus: How Long Has Spain Been on Lockdown and When Does It End?, 2020)។ ប្រជាជនអេស្ប៉ាញ មិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីផ្ទះនោះទេ លើកលែងតែពួកគេត្រូវចេញទៅទិញរបស់របរ ដែលត្រូវការជាចាំបាច់ដូចជាអាហារ និងថ្នាំពេទ្យ ឬទៅធ្វើការងារ ដែលមិនអាចធ្វើនៅផ្ទះបាន។ រដ្ឋាភិបាល ក៏បានប្រកាសអំពីកញ្ចប់ថវិកាជំនួយចំនួន ២០០ ពាន់លានអឺរ៉ូ (ប្រមាណ២២០ ពាន់លានដុល្លារអាមេរិក) ដើម្បីជួយប្រជាជន និងអាជីវកម្មដែលរងគ្រោះដោយវីរុសនេះ។ ស្រដៀងគ្នានេះ រដ្ឋាភិបាលអាល្លឺម៉ង់ បានចេញបទបញ្ជាដោយមិនអនុញ្ញាតឱ្យអ្នកដំណើរណាដែលចាកចេញពីប្រទេសដែលមិនស្ថិតនៅតំបន់ Schengen ចូលមកប្រទេសអាល្លឺម៉ង់ឡើយ លើកលែងតែជាអ្នកជំនាញ និងអ្នកស្រាវជ្រាវវេជ្ជសាស្ត្រ ប្រជាជនរស់នៅអចិន្ត្រៃយ៍នៅប្រទេសបារាំង នៅប្រទេសជាសមាជិកតំបន់សេដ្ឋកិច្ចអឺរ៉ុប និងនៅប្រទេសស្វីស និងអ្នកកាន់លិខិតឆ្លងដែនរបស់អង់គ្លេស (Coronavirus: Travel Restrictions, Border Shutdowns by Country, 2020)។ បារាំង និងអាល្លឺម៉ង់អនុវត្ត វិធីសាស្ត្រការរឹតត្បិតការធ្វើដំណើរស្ទើរតែដូចគ្នាទាំងស្រុង។ អ្នកដំណើរដែលចាកចេញពីប្រទេសនានាដែលនៅក្រៅតំបន់ Schengen នឹងមិនត្រូវបានអនុញ្ញាតឱ្យចូលប្រទេសបារាំងឡើយ ដោយមានករណីលើកលែងដូចប្រទេសអាល្លឺម៉ង់ដែរ។ បច្ចុប្បន្នប្រទេសបារាំងទាំងមូល កំពុងស្ថិតនៅក្រោមការបិទទ្វារយ៉ាងតឹងរឹង ខណៈដែលសាលារៀន និងអាជីវកម្មនានាកំពុងបិទទ្វារម្តងមួយៗបន្តគ្នា។

ក្រឡេកពីអឺរ៉ុបទៅមើលកន្លែងដំបូងនៃការផ្ទុះវីរុសវិញ ប្រទេសចិនត្រូវបានមនុស្សជាច្រើនចាត់ទុកថាជាគំរូជោគជ័យនៃការទប់ស្កាត់ជំងឺនេះ។ ចាប់តាំងពីការបិទទ្វារនៃទីក្រុងវូហានទាំងមូល អាជ្ញាធរចិនបាន និងកំពុងតាមដានយ៉ាងជិតដល់នូវចលនារបស់ប្រជាជនតាមរយៈការបង្ហោះដ្រូន ហើយថែម

ទាំងស្រែកប្រាប់ប្រជាជនឱ្យនៅផ្ទះ និងពាក់ម៉ាស។ រដ្ឋាភិបាលទីក្រុងប៉េកាំង ក៏បានប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនយ៉ាងមានប្រសិទ្ធភាព តាមរយៈការអនុវត្តបច្ចេកវិទ្យាសម្គាល់មុខ (Social Recognition) និងការចាត់ថ្នាក់ប្រជាជនតាមលេខកូដពណ៌ ដោយអាស្រ័យលើហានិភ័យនៃការឆ្លងរបស់ពួកគេ (Hjelmgaard, Lyman, & Shesgreen, 2020)។ ឥឡូវនេះ ទីក្រុងវូហាន ដែលជាចំណុចកណ្តាលនៃការរាតត្បាត លែងស្ថិតនៅក្រោមការឃុំឃាំងទៀតហើយ បន្ទាប់ពីអាជ្ញាធរបានគ្រប់គ្រងដោយជោគជ័យ ដែលបាននាំឱ្យខ្សែកោងស្ថិតិអ្នកឆ្លងត្រលប់មករាបវិញ។ ដូចប្រទេសជាច្រើនទៀតនៅលើពិភពលោកដែរ ទោះជាយ៉ាងណាក៏ដោយការប្រយុទ្ធប្រឆាំងនឹងមេរោគឆ្លងរបស់ចិននៅតែបន្តកើតមាន។ ក្រសួងការបរទេសចិននាថ្ងៃទី២៦ ខែមីនា បានប្រកាសពីការរឹតត្បិតការធ្វើដំណើរទ្រង់ទ្រាយធំ ដែលបានហាមឃាត់ការធ្វើដំណើររបស់ជនបរទេស ដែលមានបំណងចូលមកប្រទេសចិន បើទោះបីជាពួកគេកាន់ទិដ្ឋាការចិន ឬលិខិតអនុញ្ញាតស្នាក់នៅជាអចិន្ត្រៃយ៍នៅប្រទេសចិនក៏ដោយ។ ប៉ុន្តែការរឹតត្បិតថ្មីនេះ មិនមានឥទ្ធិពលលើបុគ្គលិកការទូត និងប្រជាជនដែលមានបំណងចាំបាច់មកធ្វើសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ ឬបច្ចេកវិទ្យា ឬតម្រូវការបន្ទាន់នៃមនុស្សធម៌នោះទេ (Ministry of Foreign Affairs of the People's Republic of China [FMPRC], 2020)។ ទោះបីជារដ្ឋាភិបាលចិន មិនទាន់បានបញ្ចេញកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ចដូចប្រទេសដទៃទៀតក៏ដោយ រដ្ឋាភិបាលចិន កំពុងជំរុញឱ្យធនាគារទាំងអស់របស់ខ្លួន ពន្យារការទូទាត់ប្រាក់កម្ចី។

សម្រាប់តំបន់អាស៊ានវិញ ការឆ្លងនៃជំងឺកូវីដ១៩ អាចមានទម្រង់ខុសគ្នាៗក្នុងចំណោមប្រទេសជាសមាជិកអង្គការតំបន់អាស៊ីអាគ្នេយ៍ទាំងអស់ រដ្ឋសមាជិកនីមួយៗបានព្យាយាមអភិវឌ្ឍ និងដាក់ចេញនូវវិធានការខុសៗគ្នាទៅតាមស្ថានភាពនៃការឆ្លងតាមប្រទេសរៀងៗខ្លួន។ ប្រទេសម៉ាឡេស៊ី ឈរនៅលំដាប់កំពូលនៅក្នុងតំបន់អាស៊ាន ដែលមានករណីឆ្លងចំនួន ៣.៣៣៣ ករណី និងករណីស្លាប់ចំនួន ៧៦៧ ករណី[4] គិតត្រឹមថ្ងៃសរសេរអត្ថបទនេះ។ ដោយសារស្ថានការណ៍ជំងឺកូវីដ១៩ នៅម៉ាឡេស៊ី មិនទាន់បង្ហាញសញ្ញានៃការធូរស្រាលនៅឡើយ រដ្ឋាភិបាលបានប្រកាសពន្យារពេលការរឹតបន្តឹងការធ្វើដំណើរនៅទូទាំងប្រទេសរយៈពេល ២ សប្តាហ៍ទៀតរហូតដល់ថ្ងៃទី១៤ ខែមេសា បន្ទាប់ពីវិធានការមុនៗមិនមានប្រសិទ្ធិភាព។ ការបិទការធ្វើដំណើរនេះ នឹងរឹតត្បិតការធ្វើដំណើរផ្លាស់ទី និងការជួបជុំនៅទីសាធារណៈ ហើយកម្លាំងប្រដាប់អាវុធត្រូវបានដាក់ពង្រាយ ដើម្បីឃ្លាំមើលការរឹតបន្តឹងនេះ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាល បានបង្កើនកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ចពី ២០ពាន់លាន ដល់២៥០ពាន់លានរីងហ្គីត (ប្រមាណ ៥៨ពាន់លានដុល្លារអាមេរិក) និងថវិកាចំនួន ១ពាន់លានរីងហ្គីតបន្ថែមទៀតដល់ក្រសួងសុខាភិបាល សម្រាប់ឧបករណ៍វេជ្ជសាស្ត្រ ដែលការចំណាយសរុបរបស់ក្រសួងសុខាភិបាលមានដល់ទៅ ១,៥ ពាន់លានរីងហ្គីត ស្មើនឹងប្រមាណ ៣៥០ លានដុល្លារអាមេរិក (New Straits Times, 2020)។ ដូចប្រទេសដទៃទៀតដែរ ម៉ាឡេស៊ី ក៏បានរារាំងការធ្វើដំណើររបស់ជនបរទេសចូលមកក្នុងប្រទេសខ្លួន និងការចាកចេញរបស់ប្រជាជនស្នាក់នៅអចិន្ត្រៃយ៍របស់ខ្លួន (MFAIC, 2020)។ ប្រជាជនទាំងអស់ដែលទើបតែវិលត្រឡប់ចូលប្រទេសវិញ នឹងត្រូវអនុវត្តតាមនីតិវិធីនៃវិធានចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ លើសពីនេះ ស្ថាប័នអប់រំគ្រប់លំដាប់ថ្នាក់ ត្រូវបានបញ្ជាឱ្យបិទបណ្តោះអាសន្ន។

[4] បច្ចុប្បន្នភាពតួលេខត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ម៉ោង ១៤:៤៩ GMT ដោយគេហទំព័រ Worldometer។

បន្ទាប់ពីប្រទេសម៉ាឡេស៊ី ហ្វីលីពីនស្ថិតនៅលំដាប់ទី២ ដោយមានករណីឆ្លងចំនួន ៣.០១៨[5] ករណី ហើយបន្ទាប់មកមានថៃ ឥណ្ឌូណេស៊ី និងសិង្ហបុរី ដែលសុទ្ធតែមានករណីឆ្លងជាងមួយពាន់ករណី។ ប្រធានាធិបតីហ្វីលីពីន បានបិទការធ្វើដំណើរក្នុងកោះលូហ្សុន (Luzon) របស់ហ្វីលីពីនរហូតដល់ថ្ងៃទី១២ ខែមេសា តែអាចនឹងពន្យារពេលក្នុងការបើកដំណើរការវិញ។ ការចេញទិដ្ឋាការត្រូវបានផ្អាក ហើយសាលារៀនទាំងអស់ត្រូវបានបញ្ជាឱ្យបិទរហូតដល់ថ្ងៃទី១៤ ខែមេសា។ ចំពោះស្ថានភាពនៅក្នុងប្រទេសសិង្ហបុរីវិញ ភ្ញៀវទេសចរណាដែលបានធ្វើដំណើរទៅកាន់ប្រទេសអ៊ីតាលី អេស្ប៉ាញ អាល្លឺម៉ង់ និងបារាំងក្នុងរយៈពេល១៤ថ្ងៃចុងក្រោយ នឹងមិនត្រូវបានអនុញ្ញាតឱ្យចូលសិង្ហបុរីឡើយ រាប់ទាំងការធ្វើដំណើរចូលមកប្រទេស និងការប្តូរជើងយន្តហោះ ខណៈនាវាទេសចរណ៍គ្រប់ប្រភេទមិនត្រូវបានអនុញ្ញាតឱ្យមានចូលចតនៅកំពង់ផែរបស់ខ្លួនឡើយសម្រាប់ពេលវេលានេះ។ នាពេលបច្ចុប្បន្ននេះ នៅសិង្ហបុរី ជនណាដែលរំលោភបំពានបទបញ្ជាគម្លាតសុវត្ថិភាពនឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់រហូតដល់ ៧.០០០ ដុល្លារអាមេរិក ឬជាប់ពន្ធនាគាររហូតដល់៦ខែ។ រដ្ឋាភិបាលសិង្ហបុរីបានចេញកញ្ចប់ថវិកាចំនួន ៣៣ ពាន់លាន ដុល្លារអាមេរិក ដើម្បីស្តារសេដ្ឋកិច្ចចៀសវាងពីការដួលរលំ (Dez Shira & Associates, 2020)។

ចំណែកឯប្រទេសថៃ និងឥណ្ឌូនេស៊ី ដែលមានចំនួនករណីឆ្លងប្រហាក់ប្រហែលគ្នា កំពុងស្ថិតក្នុងស្ថានភាពជាក់ប្រទេសក្នុងគ្រាអាសន្ន។ ថៃត្រូវបានស្ថិតក្នុងស្ថានភាពនៃគ្រាអាសន្នរហូតដល់ថ្ងៃទី៣០ ខែមេសា បើយោងតាមសេចក្តីប្រកាសជាផ្លូវការពីរដ្ឋាភិបាលថៃចុះថ្ងៃទី២៦ ខែមីនា (Techakitteranun, 2020)។ លើសពីនេះទៀត អភិបាលទីក្រុងបាងកក បានចុះហត្ថលេខាយល់ព្រមលើបទបញ្ជាបិទហាងលក់ទំនិញ ផ្សារ សាលារៀន និងពហុកីឡដ្ឋាន លើកលែងតែភោជនីយដ្ឋានដែលមានសេវាកម្មដឹកជញ្ជូនដល់ផ្ទះ ផ្សារទំនើប ហាងលក់ថ្នាំពេទ្យ និងទីផ្សារលក់ម្ហូបអាហារ។ ថៃ ក៏នឹងផ្អាករាល់ការចេញទិដ្ឋាការលើការមកដល់ (Visa on Arrival) និងការលើកលែងទិដ្ឋាការ សម្រាប់ប្រទេសដែលធ្លាប់ទទួលបានបុព្វសិទ្ធិនេះពីមុនមក (Dez Shira & Associates, 2020)។ សាធារណរដ្ឋឥណ្ឌូណេស៊ីនាពេលបច្ចុប្បន្ន ក៏កំពុងស្ថិតនៅក្នុងស្ថានភាពអាសន្នយ៉ាងហោចណាស់រហូតដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០។ ដើម្បីទប់ស្កាត់ការរីករាលដាល រដ្ឋាភិបាលបានកែប្រែភូមិអត្តពលកម្មមួយនៅទីក្រុងហ្សាកាតា ដើម្បីធ្វើជាមន្ទីរពេទ្យសម្រាប់ផ្ទុកអ្នកជំងឺកូវីដ១៩ ដែលមានសមត្ថភាពអាចផ្ទុកអ្នកជំងឺរហូតដល់២២.០០០នាក់។ ក្រៅពីនេះ ដើម្បីទប់ស្កាត់ការនាំចូលនៃករណីឆ្លង រដ្ឋាភិបាលឥណ្ឌូណេស៊ីបានបញ្ជាឱ្យផ្អាកការផ្តល់ទិដ្ឋាការ សម្រាប់ប្រទេសទាំងអស់រយៈពេលមួយខែ និងការហាមឃាត់ការធ្វើដំណើរចូលមកប្រទេសឥណ្ឌូណេស៊ី សម្រាប់អ្នកដែលមានប្រវត្តិធ្វើដំណើរទៅកាន់ប្រទេសនានា ដែលឆ្លងមេរោគច្រើនជាងគេលើពិភពលោក។ រាជរដ្ឋាភិបាល បានត្រៀមថវិកាចំនួន ២៤,៨ ពាន់លានដុល្លារអាមេរិក ដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ១៩ (Dezan Shira & Associates, 2020) ។

ប្រទេស CLMV (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) និងប្រ៊ុយណេ បច្ចុប្បន្នជាប្រទេសដែលមានឆ្លងករណីឆ្លងជំងឺកូវីដ១៩ តិចជាងគេក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ យ៉ាងណាមិញ ប្រទេសទាំងនេះ ក៏កំពុងអនុវត្តវិធានការបង្ការ និងការទប់ស្កាត់យ៉ាងតឹងរឹងសម្រាប់ការប្រយុទ្ធនឹងជំងឺលោកសួតកូវីដ១៩។ ជាឧទាហរណ៍ រដ្ឋាភិបាលប្រ៊ុយណេ បានដាក់

[5] បច្ចុប្បន្នភាពតួលេខត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ម៉ោង ១៤:៤៩ GMT ដោយគេហទំព័រ Worldometer។

កំហិតលើការធ្វើដំណើររបស់ពលរដ្ឋខ្លួន និងហាមជនបរទេស ដែលកំពុងស្នាក់នៅក្នុងប្រទេសខ្លួន មិនឱ្យចាកចេញពីប្រទេស ខណៈពេលដែលភ្ញៀវទេសចរមកពីខេត្ត Zhejiang និង Jiangzhu ត្រូវបានហាមឃាត់មិនឱ្យចូលក្នុងប្រទេស ដោយលើកលែងអ្នកដំណើរជាជនជាតិប្រ៊ុយណេ (Dezan Shira & Associates, 2020)។ លើសពីនេះ ការជួបជុំនៅទីសាធារណៈ ក៏ត្រូវបានហាមឃាត់ ហើយជនណាដែលបំពានបទបញ្ជា នឹងត្រូវពិន័យជាទឹកប្រាក់១ម៉ឺនដុល្លារប្រ៊ុយណេ និង/ឬប្រឈមនឹងការដាប់ពន្ធនាគាររយៈពេល៦ខែ (MFAIC, 2020)។ ចំណែកឯនៅឡាវវិញ រដ្ឋាភិបាលបានបញ្ជាឱ្យបិទច្រកទ្វារអន្តរជាតិ ដោយរារាំងប្រជាជនមិនឱ្យចាកចេញ និងចូលប្រទេសរបស់ខ្លួន។ តំបន់ត្រីកោណមាស ដែលមានព្រំប្រទល់ជាប់ ចិន និងមីយ៉ាន់ម៉ា ក៏ត្រូវបានបិទដូចគ្នា។ រដ្ឋាភិបាលបានកំណត់តម្លៃលើម៉ាសការពារ ដោយម៉ាសបីស្រទាប់ដែលមានចំនួន៥០ម៉ាសក្នុងមួយប្រអប់ មិនត្រូវលក់លើសពីតម្លៃ ២,៨២ ដុល្លារអាមេរិក ហើយម៉ាសរាយមួយ មិនត្រូវលក់លើស ០,១ ដុល្លារអាមេរិកឡើយ ដើម្បីទប់ស្កាត់ការឡើងថ្លៃ។ នៅក្នុងប្រទេសមីយ៉ាន់ម៉ា ចាប់ពីថ្ងៃទី២៥ ខែមីនា អ្នកដែលបានធ្វើដំណើរទៅក្រៅប្រទេសក្នុងពេលថ្មីៗ រួមមានអ្នកទេសចរ ប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលមានបំណងត្រឡប់ចូលក្នុងប្រទេស ត្រូវមានលិខិតបញ្ជាក់ពីការពិនិត្យសុខភាពទទួលស្គាល់ដោយក្រសួងសុខាភិបាល មិនត្រូវលើសពី ៧២ ម៉ោង រាប់ចាប់ពីពេលវេលាត្រូវធ្វើដំណើរ (MFAIC, 2020)។ មីយ៉ាន់ម៉ា ក៏បានផ្អាកផ្តល់ទិដ្ឋាការពេលមកដល់ សម្រាប់អ្នកដំណើរទាំងអស់ដែលធ្វើដំណើរមកពីប្រទេសចិន។ ក្រៅពីនេះ ក្រសួងសុខាភិបាលមីយ៉ាន់ម៉ា បានត្រៀមថវិកាប្រមាណ ២០ម៉ឺនដុល្លារអាមេរិកសម្រាប់ការផ្គត់ផ្គង់បរិក្ខារសុខាភិបាល (Dezan Shira & Associates, 2020)។ ម៉្យាងវិញទៀត នាយករដ្ឋមន្ត្រីវៀតណាមបានប្រកាសជំងឺកូវីដ១៩ ជាជំងឺរាតត្បាតទូទាំងប្រទេស និងដាក់បទបញ្ជាអំពីការអនុវត្តគម្លាតសុវត្ថិភាពទូទាំងប្រទេសរយៈពេល ១៥ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ដោយសារករណីឆ្លងនៅតែបន្តកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ (Dezan Shira & Associates, 2020)។ រាល់ការជួបជុំនានា ដែលមានមនុស្សលើសពី២នាក់ឡើងទៅ ត្រូវបានហាមឃាត់ ហើយប្រជាពលរដ្ឋទូទៅត្រូវបានណែនាំឱ្យរក្សាគម្លាតពីគ្នាយ៉ាងតិចពីរម៉ែត្រនៅតាមទីសាធារណៈ។ រដ្ឋាភិបាលវៀតណាម បានប្រកាសអំពីការធ្វើតេស្តទ្រង់ទ្រាយធំបន្ទាប់ពីបាននាំចូលឧបករណ៍សម្រាប់ធ្វើតេស្តភ្លាមៗ ចំនួន ២០ម៉ឺនឈុតពីកូរ៉េខាងត្បូង។ ក្រៅពីនេះ រដ្ឋាភិបាល ក៏បានប្រកាសកញ្ចប់ថវិកាជំនួយក្នុងទឹកប្រាក់ចំនួន១,១៦ពាន់លានដុល្លារអាមេរិក ដើម្បីជួយដល់អាជីវកម្មក្នុងស្រុកដែលរងគ្រោះដោយសារជំងឺរាតត្បាតកូវីដ១៩ (*"Vietnam Announces $1.16bln Stimulus Package to Help Virus-hit Businesses -state media"*, 2020)។

### ❖ វិធានការកម្ពុជាប្រយុទ្ធនឹងជំងឺកូវីដ១៩

កម្ពុជា មិនគេចផុតឡើយពីការរីករាលនៃជំងឺកូវីដ១៩ និងរងផលប៉ះពាល់របស់វា។ យោងតាមការព្យាកររបស់ធនាគារអភិវឌ្ឍន៍អាស៊ី កម្ពុជាអាចនឹងទទួលរងនូវផលប៉ះពាល់ខាងសេដ្ឋកិច្ចអាក្រក់បំផុត ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដោយប្រៀបធៀបលើភាគរយនៃការបាត់បង់សេដ្ឋកិច្ច និងផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា (Abiad et al., 2020)។ របាយការណ៍ធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញថា កម្ពុជានឹងខាតបង់ប្រមាណជា ៣៩០ លានដុល្លារអាមេរិក ដែលស្មើនឹង ១,១៥ ភាគរយនៃផលិតផលសរុបក្នុងស្រុករបស់ខ្លួន។ បន្ទាប់ពីកម្ពុជា ប្រទេសថៃ ត្រូវបានគេព្យាករថានឹងជាប្រទេសលំដាប់ទី២ ដែលនឹងទទួលរងផលប៉ះពាល់ពីជំងឺកូវីដ១៩ យ៉ាងខ្លាំងលើសេដ្ឋកិច្ចជាតិរបស់ខ្លួន ដែលមានចំនួនជិតស្មើនឹង ១,១១ភាគរយនៃផលិតផលក្នុងស្រុកសរុប ខណៈ

ដែលប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ នឹងទទួលការខាតបង់យ៉ាងហោចណាស់ ០,៥ ភាគរយ ឬទាបជាង ០,៥ ភាគរយនៃចំនួនផលិតផលសរុបក្នុងស្រុក (Abiad et al., 2020)។ បន្ថែមពីលើនេះ របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំដែលទើបចេញផ្សាយថ្មីៗនេះស្តីពីទស្សនវិស័យអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២០ របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករថា កម្ពុជាអាចនឹងជួបប្រទះនូវការធ្លាក់ចុះយ៉ាងខ្លាំង នៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំរបស់ខ្លួននៅឆ្នាំ២០២០ នេះ។ របាយការណ៍នេះ បានបង្ហាញថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាសម្រាប់ឆ្នាំ២០២០ អាចនឹងធ្លាក់ចុះដល់ ២,៣ ភាគរយ ហើយស្ទុះឡើងវិញមកត្រឹម ៥,៧ ភាគរយនៅឆ្នាំបន្ទាប់ ដោយផ្អែកលើការរំពឹងថារាល់សកម្មភាពសេដ្ឋកិច្ច នឹងវិលមករកភាពប្រក្រតីវិញ ហើយជំងឺរាតត្បាតនេះនឹងត្រូវបានបញ្ចប់ (ADB, 2020)។ ស្រដៀងគ្នានេះ របាយការណ៍របស់ធនាគារពិភពលោក បានចេញផ្សាយនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ កន្លងទៅ ក៏បានព្យាករអំពីស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នា ដោយផ្អែកលើការវាយតម្លៃលើកត្តាសេដ្ឋកិច្ចរបស់បណ្តាប្រទេសនៅក្នុងតំបន់អាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក ដែលមានចំនួន ២៣៤ ទំព័រ។ ធនាគារពិភពលោក បានបង្ហាញថា កំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា នឹងធ្លាក់ចុះមកត្រឹម ២,៥ ភាគរយនៅឆ្នាំ២០២០ ដែលជាការឆ្លុះបញ្ចាំងពីការរីករាលដាលនៃជំងឺកូវីដ១៩ ហើយនឹងស្ទុះងើបឡើងវិញដល់ ៥,៩ ភាគរយក្នុងឆ្នាំ២០២១ (World Bank, 2020)។ សេណារីយ៉ូដ៏អាក្រក់បំផុត ដែលព្យាករដោយធនាគារពិភពលោក មកលើសេដ្ឋកិច្ចកម្ពុជា បានបង្ហាញថា កំណើនសេដ្ឋកិច្ចកម្ពុជា អាចនឹងមានកម្រិតទាបត្រឹម ១ ភាគរយ នៅឆ្នាំ២០២០ និងអាចងើបឡើងបានត្រឹម ៣,៩ ភាគរយ នៅឆ្នាំ២០២១ នេះបើយោងតាមរបាយការណ៍ស្តីពីការវាយតម្លៃសេដ្ឋកិច្ចក្នុងបណ្តាប្រទេសនៅតំបន់អាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក។

**កម្ពុជា**

ការព្យាករកំណើនផលិតផលក្នុង




**ប្រភព៖** Asian Development Bank

តែទោះជាយ៉ាងនេះក្តី នៅជំណាក់កាលនេះ វិធានការសុខភាពដែលមានភាពច្បាស់លាស់ និងភាពទទួលខុសត្រូវខ្ពស់ ត្រូវបានគេអះអាងថា មានសារៈសំខាន់ជាងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ពីព្រោះថាសោកនាដកម្មនេះ គឺជាវិបត្តិសុខភាពសាធារណៈ។ ដូច្នេះ បើទោះបីគោលនយោបាយសារពើពន្ធ ឬរូបិយវត្ថុក្នុងស្ថានភាពបែបនេះ អាចមានភាពចាំបាច់ តែអាច

មិនមានប្រសិទ្ធិភាព និងមិនមែនជាកត្តាអាទិភាពចម្បងបំផុតនោះទេ បើប្រៀបធៀបជាមួយសុខភាព និងសុខុមាលភាពរបស់ប្រជាជន។ បើទោះបីប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសមួយគឺជាកង្វល់រួមសម្រាប់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងរាជរដ្ឋាភិបាល និងប្រជាជនផ្ទាល់ ប៉ុន្តែដំណោះស្រាយបន្ទាន់បំផុតសម្រាប់កូវីដ១៩ គឺការការពារនៃការរីករាលដាលដល់សហគមន៍ ដែលទាមទារការឆ្លើយតបទាន់ពេលវេលា និងដោយមានភាពយកចិត្តទុកដាក់ជិតដល់ជាទីបំផុត។ នៅក្នុងកាលៈទេសៈនៃកូវីដ១៩នេះ គេត្រូវការការយកចិត្តទុកដាក់ខ្លាំងបំផុតជាងពេលណាៗទាំងអស់ទៅលើប្រព័ន្ធថែទាំ និងសុខាភិបាលរបស់កម្ពុជា។ ដរាបណាវីរុសនេះ ពុំមានការទប់ស្កាត់ ហើយសាធារណជន នៅតែស្ថិតក្នុងស្ថានភាពភ័យស្លន់ស្លោ សេដ្ឋកិច្ចជាតិ នឹងមិនមានស្ថិរភាព ហើយនឹងនៅតែស្ថិតក្នុងហានិភ័យខ្ពស់។

ពេលវេលានៃភាពភ័យខ្លាច និងស្លន់ស្លោក្នុងសង្គម អំឡុងពេលរាតត្បាតរ៉ាំរ៉ៃនៃជំងឺកូវីដ១៩ កម្ពុជា ក៏ដូចជាប្រទេសជាច្រើនទៀត កំពុងតែប្រឈមមុខនឹងបញ្ហាសង្គមយ៉ាងច្រើនបន្ថែមពីលើបញ្ហាសេដ្ឋកិច្ច និងសុខភាពសាធារណៈ។ បញ្ហាធ្ងន់ធ្ងរបំផុតក្នុងចំណោមបញ្ហាទាំងនោះរួមមានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយលើបណ្តាញសង្គម ដូចជាអំពី ឧបករណ៍ធ្វើតេស្តលឿន ថ្នាំព្យាបាល ការបិទរាជធានី និងខេត្ត រួមទាំងជំនឿមិនត្រឹមត្រូវតៗគ្នាផ្សេងៗ ដូចជា ការបរិភោគស៊ុតមាន់កណ្តាលអធ្រាត្រ ដែលអាចមានប្រសិទ្ធិភាពក្នុងការការពារមនុស្សពីការឆ្លងជំងឺនេះបានជាដើម។ ក្រៅពីនេះ គេក៏ឃើញមានជនឆ្លៀតឱកាសជាច្រើនបន្តបន្ទាប់ ដែលព្យាយាមកេងចំណេញពីស្ថានភាពនៃវិបត្តិនេះ។ អ្នកប្រកបអាជីវកម្មខ្នាតតូចមួយចំនួន បានបន្តដំឡើងថ្លៃឥវ៉ាន់ចាំបាច់ ដូចជាទឹកលាងដៃ ម៉ាសការពារ អាល់កុលសម្រាប់បាញ់ និងរបស់ប្រើប្រាស់ចាំបាច់នានា ដែលមានតម្លៃខ្ពស់លើសជាងតម្លៃធម្មតា ដើម្បីផលចំណេញផ្ទាល់ខ្លួន។ លើសពីនេះ គេបង្ហាញថា មានគេហទំព័រថ្មីជាងប្រមាណ ១៦.០០០ ដែលមានមូលបទពាក់ព័ន្ធនឹងវីរុសកូរ៉ូណា ត្រូវបានចុះបញ្ជីជាបន្តបន្ទាប់តាំងពីខែមករាឆ្នាំនេះ (Scott, 2020) ។ គេហទំព័រមួយចំនួន ក្នុងចំណោមគេហទំព័រទាំងនោះ មានបំណងលក់ឧបករណ៍ក្លែងក្លាយ និងផ្តល់ការបញ្ចុះតម្លៃ នៅលើទីផ្សារងងឹត ក្នុងគោលបំណងព្យាយាមប្រមូលទិន្នន័យពីកុំព្យូទ័រផ្ទាល់ខ្លួនរបស់និយោជិត ដែលកំពុងធ្វើការពីផ្ទះ ដោយមិនសូវមានការការពារ។ សកម្មភាពអស់ទាំងនេះ ត្រូវបានអំពាវនាវឱ្យមានការរឹតបន្តឹង ការត្រួតពិនិត្យ និងការគ្រប់គ្រងពីសំណាក់រដ្ឋាភិបាលលើ ឧក្រិដ្ឋកម្មនៅលើប្រព័ន្ធអ៊ីនធឺណិត ក៏ដូចជាយន្តការកំណត់តម្លៃឱ្យបានត្រឹមត្រូវក្នុងគ្រាដ៏លំបាកមួយនេះ។

ក្នុងអំឡុងពេលនៃការសរសេរអត្ថបទនេះ សេចក្តីថ្លែងការណ៍ផ្លូវការចុងក្រោយរបស់ក្រសួងសុខាភិបាលកម្ពុជា បានបញ្ជាក់ថា ឥឡូវនេះមានករណីឆ្លងចំនួន១១៤ នៅកម្ពុជា ក្នុងនោះ ៣៥ នាក់បានជាសះស្បើយ (Ministry of Health [MoH], 2020)។ បន្ទាប់ពីមានការកើនឡើងនូវករណីឆ្លងយ៉ាងឆាប់រហ័ស សម្តេចនាយករដ្ឋមន្ត្រី បានប្រកាសថា កម្ពុជាកំពុងស្ថិតក្នុងស្ថានភាពនៃការពិចារណាថា តើត្រូវដាក់ប្រទេសក្នុងភាពអាសន្នដែរឬទេ ខណៈពេលដែលចាំបាច់ត្រូវថ្លឹងថ្លែងពីផលប៉ះពាល់ លើសិទ្ធិស៊ីវិលប្រជាជន សង្គម និងសេដ្ឋកិច្ចជាតិ ចេញពីការដាក់ប្រទេសក្នុងភាពអាសន្ន។ ទោះបីជាសម្តេចនាយករដ្ឋមន្ត្រី កំពុងពិចារណាលើជម្រើសនេះក៏ដោយ សម្តេចផ្ទាល់បានធានាថា ទីតាំងមួយចំនួនដូចជាផ្សារ ភោជនីយដ្ឋាន និងហាងកាហ្វេជាដើម នឹងមិនត្រូវបានបិទនោះទេ ពីព្រោះកន្លែងទាំងនេះ គឺជាកន្លែងដែលប្រជាជនទិញទំនិញ អាហារសម្ភារអនាម័យ សម្ភារវេជ្ជសាស្ត្រ និងរបស់ប្រើប្រាស់ចាំបាច់នានា។ នៅក្នុងសន្និសីទសារព័ត៌មានក្រោយសម័យប្រជុំពេញអង្គនៃរដ្ឋសភាកម្ពុជា នាចុងខែមីនាកន្លងទៅ សម្តេចនាយក

រដ្ឋមន្ត្រី បានអះអាងថា រដ្ឋាភិបាលបានស្តុកទុកម៉ាស និងទឹកលាងដៃមួយចំនួនធំ ក៏ដូចជាគ្រឿងផ្គត់ផ្គង់វេជ្ជសាស្ត្រផ្សេងៗទៀត ដើម្បីជួយគ្រូពេទ្យនៅជួរមុខ និងសាធារណជនទូទៅ។ សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលកម្ពុជា អំពីលទ្ធផលនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រីរបស់កម្ពុជា ដឹកនាំផ្ទាល់ដោយនាយករដ្ឋមន្ត្រី និងមានសមាសភាពចូលរួមពីឧបនាយករដ្ឋមន្ត្រីទាំងអស់ ដែលបានពិភាក្សាអំពីស្ថានភាពសេចក្តីព្រាងច្បាប់ដាក់ប្រទេសក្នុងគ្រាអាសន្ន បានបង្ហាញថា រដ្ឋាភិបាលចាត់ទុកទឹកអាល់កុល និងម៉ាសជាទំនិញយុទ្ធសាស្ត្រសម្រាប់កាលៈទេសៈនៃការរីករាលដាលនៃជំងឺកូវីដ១៩នេះ ដូច្នេះ រដ្ឋាភិបាលសម្រេចបញ្ជាទិញម៉ាសចំនួន ៥,២លានម៉ាស ក្នុងនោះមាន ៤លានម៉ាស នាំចូលមកពីបរទេស នេះបើយោងតាមសេចក្តីជូនដំណឹង[6] ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជា។

ក្រៅពីនេះ មានយន្តការជាច្រើនទៀត ដែលរដ្ឋាភិបាលកម្ពុជាបានដាក់ចេញសម្រាប់ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ នៅថ្ងៃទី១៦ ខែមីនា ក្រសួងអប់រំយុវជន និងកីឡា បានបញ្ជាឱ្យបិទគ្រឹះស្ថានអប់រំទាំងសាធារណៈ និងឯកជនជាបណ្តោះអាសន្ន ដោយប្រកាសអំពីការឈប់សម្រាកនៅរដូវក្តៅដល់សិស្ស និងនិស្សិតទូទាំងប្រទេស។ បទបញ្ជាបន្ថែមត្រូវបានធ្វើទៅលើការបិទខារ៉ាអូខេ កាស៊ីណូ រោងកុន និងពិធីជួបជុំសាសនា ដែលត្រូវបានគេយល់ថាជាហានិភ័យខ្ពស់នៃការឆ្លងជាសហគមន៍។ ក្នុងនោះដែរ គណៈកម្មាធិការជាតិថ្មីមួយ មានភារកិច្ចពិសេស ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រីផ្ទាល់ ត្រូវបានបង្កើត ដើម្បីដោះស្រាយ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ លើសពីនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានអំពាវនាវដល់សាធារណជនឱ្យចូលរួមសហការជាមួយរដ្ឋាភិបាល ជាពិសេសការបរិច្ចាគថវិកាដល់បេសកកម្មប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ១៩នេះ បើទោះបីរដ្ឋាភិបាលផ្ទាល់ បានប្រកាសថវិកាបម្រុងចំនួន៣០លានដុល្លារអាមេរិក សម្រាប់ទប់ទល់នឹងស្ថានការណ៍នេះក៏ដោយ។ ទាក់ទងនឹងបញ្ហានេះ សម្តេចតេជោនាយករដ្ឋមន្ត្រីបានជំរុញឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារទាំងអស់ ពន្យាពេលនៃការបង់ប្រាក់បំណុល និងការទូទាត់ប្រាក់កម្ចី ក៏ដូចជាធ្វើការស្នើសុំ និងព្រមានដល់អ្នកលក់ដូរ ដើម្បីកុំដំឡើងថ្លៃទំនិញចាំបាច់មួយចំនួន ដូចជាម៉ាស និងទឹកលាងដៃជាដើម បើមិនដូច្នេះទេ អាជ្ញាប័ណ្ណអាជីវកម្មរបស់ពួកគេអាចនឹងត្រូវដកហូតមួយជីវិត។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានបញ្ជាឱ្យផ្អាកនូវការនាំចេញស្រូវអង្ករទៅក្រៅប្រទេសជាបណ្តោះអាសន្ន ដើម្បីទុកបម្រុងសម្រាប់បំពេញតម្រូវការក្នុងស្រុក ខណៈពេលដែលមានការកើនឡើងនៃភាពចាំបាច់ក្នុងការស្តុកទុកស្បៀងអាហារសម្រាប់សេណារីយ៉ូនៃស្ថានការណ៍ដ៏លំបាកបំផុត ឬវិបត្តិណាមួយ ជាពិសេសក្នុងស្ថានការណ៍ដែលមានការកើនឡើងខ្ពស់នៃតម្រូវការ ដែលអាចបណ្តាលមកពីការទិញដោយស្លន់ស្លោរបស់ប្រជាពលរដ្ឋ។ ក្រៅពីនេះ រដ្ឋាភិបាលកម្ពុជា ក៏បានបញ្ជាឱ្យអភិបាលរាជធានីភ្នំពេញ និងគ្រប់អភិបាលតាមបណ្តាខេត្តទាំងអស់ ប្រើប្រាស់សណ្ឋាគារ ឬក៏សាលារៀន ជាទីកន្លែងសម្រាប់ថែទាំសុខភាពអ្នកជំងឺដែលឆ្លងជំងឺកូវីដ១៩។

ដើម្បីបន្តផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ក្រសួងសុខាភិបាលបានធ្វើសេចក្តីជូនព័ត៌មាន ស្តីពីស្ថានភាពបច្ចុប្បន្ននៃជំងឺកូវីដ១៩ នៅកម្ពុជាជារៀងរាល់ថ្ងៃ ដោយធ្វើបច្ចុប្បន្នភាពពីករណីឆ្លងថ្មី ករណីជាសះស្បើយថ្មី និងករណីសរុប។ ទន្ទឹមនឹងនេះ

[6] សូមមើលបន្ថែមនៅ Office of the Council of Minister. (31 March 2020). *Statement on the Meeting Result of Permanent Members of Cambodia's Council of Ministers.* Available at: https://pressocm.gov.kh/archives/65258។

ក៏មានការបន្តផ្សព្វផ្សាយណែនាំដល់ប្រជាជន ឱ្យអនុវត្តតាមនីតិវិធីស្តង់ដារវេជ្ជសាស្ត្រ ដើម្បីការពារ និងមើលថែខ្លួនឱ្យមានសុវត្ថិភាព ជៀសផុតពីការឆ្លងមេរោគកូរ៉ូណា តាមរយៈការលាងដៃឱ្យបានត្រឹមត្រូវ ការរក្សាគម្លាតសុវត្ថិភាព និងការប្រើប្រាស់ម៉ាសការពារជាដើម។ ក្នុងការផ្តល់សេវាថែទាំសុខភាពដល់សាធារណជន រដ្ឋាភិបាលកម្ពុជា បានបន្តផ្តល់ជូនការព្យាបាលដោយឥតគិតថ្លៃដល់អ្នកជំងឺ ទាំងក្នុងស្រុក និងជនបរទេស ដើម្បីឱ្យអ្នកជំងឺអាចទទួលបានការព្យាបាល និងជាសះស្បើយឡើងវិញ ដោយមិនចាំបាច់ព្រួយបារម្ភអំពីសេវាកម្ម និងតម្លៃនៃការព្យាបាល ដែលជាហេតុផលសំខាន់មួយ ដែលមនុស្សមួយចំនួនបានគេចវេសពីការព្យាបាល។

ដើម្បីបង្ការការរីករាលដាលបន្ថែមទៀតនៃករណីជំងឺកូវីដ១៩ ដែលភាគច្រើនជាករណីឆ្លងពីបរទេស រាជរដ្ឋាភិបាលកម្ពុជា បានចេញការរឹតបន្តឹងការធ្វើដំណើរ ចំពោះអ្នកដំណើរមកពីប្រទេសចំនួន ៦ រួមមាន សហរដ្ឋអាមេរិក អាល្លឺម៉ង់ បារាំង អេស្ប៉ាញ អ៊ីតាលី និងអ៊ីរ៉ង់ មិនឱ្យចូលក្នុងប្រទេស ក៏ដូចជាណែនាំដល់ប្រជាជនកម្ពុជាទាំងអស់ ឱ្យចៀសវាងការធ្វើដំណើរទៅអឺរ៉ុប សហរដ្ឋអាមេរិក និងអ៊ីរ៉ង់។ សេចក្តីប្រកាសព័ត៌មាន[7]ចុងក្រោយបំផុតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចេញផ្សាយនៅថ្ងៃទី២៨ ខែមីនា បានប្រកាសពីការសម្រេចរបស់រដ្ឋាភិបាល សម្រាប់ការព្យួរការចេញទិដ្ឋាការអេឡិចត្រូនិក និងទិដ្ឋាការនៅពេលមកដល់ សម្រាប់ជនបរទេសទាំងអស់ក្នុងរយៈពេលមួយខែ ខណៈពេលដែលជនបរទេសទាំងអស់ដែលមានបំណងចូលកម្ពុជា ក្នុងពេលកំណត់នេះ ត្រូវមានទិដ្ឋាការជាមុន ផ្តល់ដោយស្ថានបេសកកម្មការទូតរបស់កម្ពុជានៅបរទេស។ ក្នុងនោះដែរ សេចក្តីប្រកាសព័ត៌មាននេះ បានកំណត់លក្ខខណ្ឌយ៉ាងតិចចំនួន ២ បន្ថែមទៀត សម្រាប់ភ្ញៀវទេសចរទាំងអស់ ដែលមានបំណងចូលក្នុងប្រទេសកម្ពុជា ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាព ដែលមានរយៈពេលមិនលើសពី ៧២ម៉ោង នៃថ្ងៃចេញដំណើរដែលបង្ហាញថា អ្នកទាំងនោះមិនមានផ្ទុកវីរុសកូរ៉ូណា ហើយត្រូវមានប្រាក់ធានារ៉ាប់រងសុខភាពយ៉ាងតិចចំនួន ៥ម៉ឺនដុល្លារអាមេរិកក្នុងអំឡុងពេលស្នាក់នៅកម្ពុជា។ ម៉្យាងវិញទៀត ដើម្បីជួយសម្រួលដល់ភ្ញៀវទេសចរបរទេស ដែលមិនអាចវិលត្រឡប់ទៅប្រទេសកំណើតវិញ ព្រោះស្ទើរគ្រប់ក្រុមហ៊ុនអាកាសចរទាំងអស់ ត្រូវបានផ្អាកជើងហោះហើរ រាជរដ្ឋាភិបាលកម្ពុជា បានចេញបទបញ្ជាថ្មីក្នុងការផ្តល់ការពន្យាទិដ្ឋាការទេសចរណ៍ ដោយស្វ័យប្រវត្តិ ដល់ភ្ញៀវទេសចរបរទេសទាំងអស់ ដែលបានមកដល់កម្ពុជា បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ពួកគេអាចរកបានជើងហោះហើរត្រឡប់មកមាតុភូមិវិញបាន នេះបើយោងតាមកំណត់ទូត ចេញផ្សាយនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ផ្ញើទៅកាន់ស្ថានបេសកកម្មការទូត និងស្ថានកុងស៊ុលបរទេសទាំងអស់ នៅព្រះរាជាណាចក្រកម្ពុជា និងចម្លងជូនស្ថានបេសកកម្មការទូតកម្ពុជានៅបរទេសទាំងអស់[8]។

រដ្ឋាភិបាល យល់ពីការលំបាករបស់ប្រជាជនក្នុងអំឡុងពេលជំងឺរាតត្បាតនេះ ទាំងផ្លូវចិត្ត និងហិរញ្ញវត្ថុ។ នេះជាមូលហេតុដែលរដ្ឋាភិបាល បានសម្រេចប្រកាសការលើកលែងពន្ធរយៈពេលបីខែ សម្រាប់អាជីវកម្មក្នុងវិស័យទេសចរណ៍ ក្នុងគោលបំណងកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ ដែលពួកគេកំពុងជួបប្រទះបន្ថែមពីលើការបាត់បង់ប្រាក់ចំណូលនាពេលនេះ។ ក្នុងពេលសរសេរអត្ថបទមកដល់ផ្នែកចុងក្រោយនេះ កម្ពុជាកំពុងស្ថិត

[7] សូមមើលបន្ថែមនៅ Ministry of Foreign Affairs and International Cooperation. (28 March, 2020). *Travel Restrictions Issued by the Royal Government of Cambodia in Relation to the Novel Coronavirus (COVID-19).* Available at: https://www.mfaic.gov.kh/site/detail/41728

[8] កំណត់ទូតនេះ បានត្រូវបានបង្ហោះនៅលើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០។

ក្នុងដំណាក់កាលនៃការពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការដាក់ប្រទេសក្នុងគ្រាអាសន្ន ដែលត្រូវរំពឹងថានឹងត្រូវបានអនុម័តដោយសមាជិករដ្ឋសភាកម្ពុជា នៅក្នុងសម័យប្រជុំពេញអង្គបន្ទាប់នាពេលដ៏ឆាប់ខាងមុខនេះ។ បើទោះបីជាមានសេចក្តីព្រាងច្បាប់ស្តីពីការដាក់ប្រទេសក្នុងគ្រាអាសន្ន ដែលមានការស្នើ ការអនុម័ត និងការប្រកាសឱ្យប្រើប្រាស់ខាងមុខក្តី ស្ថានភាពបច្ចុប្បន្ននៃជំងឺកូវីដ១៩នៅកម្ពុជា មែនទែនទៅ ពុំទាន់មានភាពចាំបាច់ក្នុងការប្រកាសពីស្ថានភាពក្នុងគ្រាអាសន្ននោះទេ។ ទោះជាយ៉ាងណា នេះគឺជាការរៀបចំសម្រាប់ស្ថានភាពអាក្រក់បំផុត ដែលមិនមើលឃើញទុកជាមុនបាន នៅក្នុងពេលវេលានៃការរីករាលដាលនៃជំងឺកូវីដ១៩នេះ។ ជំងឺរលាកផ្លូវដង្ហើមកូវីដ១៩ បានធ្វើឱ្យអ្វីៗគ្រប់យ៉ាងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងមិនអាចទាយទុកជាមុនបាន រួមទាំងពេលវេលាណាដែលស្ថានភាពជំងឺកូវីដ១៩នៅកម្ពុជានឹងអាចស្ថិតនៅក្រោមការគ្រប់គ្រងបានពេញលេញ ដោយមិនចាំបាច់ត្រូវការការដាក់ប្រទេសក្នុងគ្រាអាសន្ន ឬពេលដែលស្ថានភាពនៃវិបត្តិណានេះកាន់តែយ៉ាប់យ៉ឺនទៅ ដែលតម្រូវឱ្យមានភាពចាំបាច់បំផុតក្នុងការដាក់ប្រទេសក្នុងគ្រាអាសន្ន ដើម្បីអាចគ្រប់គ្រង និងធ្វើឱ្យស្ថានការណ៍មានស្ថិរភាពឡើងវិញ។

## *ឯកសារយោង*


*'Happily surprised'? Trump says Russia sent US 'very, very large' aid package to combat Covid-19*. (31 March, 2020). Retrieved from RT: https://www.rt.com/usa/484536-trump-russia-aid-coronavirus/

Abiad, A., Arao, R. M., Dagli, S., Ferrarini, B., Noy, I., Osewe, P., … Platitas, R. (06 March, 2020). The Economic Impact of the COVID-19 Outbreak on Developing Asia. *Asian Development Bank*. Retrieved from https://www.adb.org/publications/economic-impact-covid19-developing-asia

Al Jazeera. (23 March, 2020). *Trump defends calling coronavirus the 'Chinese virus'.* Retrieved from https://www.aljazeera.com/programmes/newsfeed/2020/03/trump-defends-calling-coronavirus-chinese-virus-200323102618665.html

Allemandou, S. (23 March, 2020). Post-traumatic stress, confusion and anger: How quarantine affects your mental health. France24. Retrieved from https://www.france24.com/en/20200323-post-traumatic-stress-confusion-and-anger-how-quarantine-affects-your-mental-health

Asian Development Bank [ADB]. (03 April, 2020). *Cambodia's Economic Growth to Slow in 2020, Rebound Expected in 2021 — ADB.* Retrieved from https://www.adb.org/news/cambodias-economic-growth-slow-2020-rebound-expected-2021-adb

BBC. (13 March, 2020). Coronavirus: Food bank shortage blamed on panic buying. *BBC.* Retrieved from https://www.bbc.com/news/uk-england-london-51837892

Bekiempis, V. (23 March, 2020). 'Could you buy a little less, please?': panic-buying disrupts food distribution. *The Guardian.* Retrieved from: https://www.theguardian.com/world/2020/mar/23/us-coronavirus-panic-buying-food

Betti, F. & Ni, J. (23 March, 2020). How China can rebuild global supply chain resilience after COVID-19. *World Economic Forum.* Retrieved from https://www.weforum.org/agenda/2020/03/coronavirus-and-global-supply-chains/

Breuninger, K. (23 March, 2020). Trump says businesses could reopen — soon — while

fighting coronavirus. *CNBC.* Retrieved from https://www.cnbc.com/2020/03/23/coronavirus-trump-says-businesses-could-reopen-soon-while-fighting-covid.html

Brun, H. M. (14 March, 2020). Coronavirus and the antifragile supply chain. *Supply Chain Digital.* Retrieved from https://www.supplychaindigital.com/supply-chain-management/coronavirus-and-antifragile-supply-chain

Castillo, J. (22 March, 2020). Spain announces 30-day travel restrictions. *BBC*. Retrieved from https://edition.cnn.com/world/live-news/coronavirus-outbreak-03-22-20/h_16ac50f4a399975c647d0c5380a497c8

*Coronavirus: How long has Spain been on lockdown and when does it end?*. (26 March, 2020). Retrieved from AS English: https://en.as.com/en/2020/03/26/other_sports/1585233133_070352.html#menu

*Coronavirus: Italy extends emergency measures nationwide.* (10 March, 2020). Retrieved from BBC: https://www.bbc.com/news/world-europe-51810673

Craven, M., Liu, L., Mysore, M. & Wilson, M. (March, 2020). *COVID-19: Implications for business.* Retrieved from McKinsey & Company: https://www.mckinsey.com/business-functions/risk/our-insights/covid-19-implications-for-business.

Deutsche Welle. (30 March, 2020). *Economic advisers: Coronavirus may see German GDP dip by over 5%.* Retrieved from https://www.dw.com/en/economic-advisers-coronavirus-may-see-german-gdp-dip-by-over-5/a-52952713

*Domestic violence cases jump 30% during lockdown in France.* (28 March, 2020). Retrieved from Euronews: https://www.euronews.com/2020/03/28/domestic-violence-cases-jump-30-during-lockdown-in-france?utm_term=Autofeed&utm_medium=Social&utm_source=Facebook&fbclid=IwAR0eclWZ0sGx6LR17aJydVLuhSMHhglmS6Fn3vkZO4Qt6Q6keBc27ysyUdo#Echobox=1585376018

Faus, J. (17 March, 2020). This is how coronavirus could affect the travel and tourism industry. *World Economic Forum.* Retrieved from https://www.weforum.org/agenda/2020/03/world-travel-coronavirus-covid19-jobs-pandemic-tourism-aviation/

Himel, J. (09 March, 2020). The Asian Development Bank maps out economic impacts of various scenarios as the coronavirus spreads to over 70 countries. *Thmey Thmey.* Retrieved from https://cambodianess.com/article/how-will-covid-19-affect-cambodias-economy

Hjelmgaard, K., Lyman, J. E., & Shesgreen, D. (01 April, 2020). This is what China did to beat coronavirus. Experts say America couldn't handle it. *USA Today.* Retrieved from https://www.usatoday.com/story/news/world/2020/04/01/coronavirus-covid-19-china-radical-measures-lockdowns-mass-quarantines/2938374001/

Jackson, K. J., Weiss, A. M., Schwarzenberg, B. A., & Nelson, M. R. (26 March, 2020). Global Economic Effects of COVID-19. *Congressional Research Service.* Retrieved from https://fas.org/sgp/crs/row/R46270.pdf

KBS World Radio. (24 March, 2020). *IMF Chief: Coronavirus-led Recession Could be Worse Than 2008 Crisis.* Retrieved from

http://world.kbs.co.kr/service/news_view.htm?lang=e&Seq_Code=152244

Klayman, B. (24 March, 2020). G7 offers hope global economic decline easing. *Reuters.* Retrieved from https://www.reuters.com/article/us-financial/g7-offers-hope-global-economic-decline-easing-idUSTRE53M5YG20090424

Lappeman, J. (22 March, 2020). Panic buying in the wake of COVID-19 underscores inequalities in South Africa. *The Conversation.* Retrieved from http://theconversation.com/panic-buying-in-the-wake-of-covid-19-underscores-inequalities-in-south-africa-134172

Ljunggren, D. (25 March, 2020). Canada doubles value of coronavirus stimulus package, promises cash, loan delays. *Reuters.* Retrieved from https://www.reuters.com/article/us-health-ccoronavirus-canada/canada-doubles-value-of-coronavirus-stimulus-package-promises-cash-loan-delays-idUSKBN21C1QO

Lufkin, B. (05 March, 2020). Coronavirus: The psychology of panic buying. *BBC.* Retrieved from https://www.bbc.com/worklife/article/20200304-coronavirus-covid-19-update-why-people-are-stockpiling

MFAIC. (01 April, 2020). *Announcement on measures imposed by ASEAN member countries to tackle the spread of Coronavirus on 1 April 2020.* Retrieved from https://www.mfaic.gov.kh/site/detail/41759

Ministry of Foreign Affairs of the People's Republic of China. (26 March, 2020). *Ministry of Foreign Affairs of the People's Republic of China National Immigration Administration Announcement on the Temporary Suspension of Entry by Foreign Nationals Holding Valid Chinese Visas or Residence Permits.* Retrieved from https://www.fmprc.gov.cn/mfa_eng/wjbxw/t1761867.shtml

Ministry of Health Cambodia. (29 March, 2020). *Press Release.*

National Institute of Health. (16 March, 2020). *NIH clinical trial of investigational vaccine for COVID-19 begins.* Retrieved from https://www.nih.gov/news-events/news-releases/nih-clinical-trial-investigational-vaccine-covid-19-begins

New Straits Times. (28 March, 2020). *PM's full speech on Prihatin Economic Stimulus Package.* Retrieved from https://www.nst.com.my/news/nation/2020/03/578956/pms-full-speech-prihatin-economic-stimulus-package

Pettinger, T. (n.d.). Economic costs of unemployment. *Economicshelp.org.* Retrieved from https://www.economicshelp.org/macroeconomics/unemployment/costs/

Pramuk, J. (27 March, 2020). Trump signs $2 trillion coronavirus relief bill as the US tries to prevent economic devastation. *CNBC.* Retrieved from https://www.cnbc.com/2020/03/27/house-passes-2-trillion-coronavirus-stimulus-bill-sends-it-to-trump.html

PwC. (n.d.). COVID-19: Operations and supply chain disruption. Retrieved from https://www.pwc.com/us/en/library/covid-19/supply-chain.html

Reuters. (31 March, 2020). Coronavirus school closures worldwide. Retrieved from https://graphics.reuters.com/HEALTH-

CORONAVIRUS-SCHOOLS/0100B5KQ43K/index.html

Reynolds, M. (17 March, 2020). What is coronavirus and what happens now it is a pandemic? *Wired*. Retrieved from https://www.wired.co.uk/article/china-coronavirus

Rowling, M. (26 March, 2020). UN aid chief on coronavirus: 'No one is safe until everyone is safe'. *World Economic Forum.* Retrieved from https://www.weforum.org/agenda/2020/03/coronavirus-united-nations-covid19-pandemic-health-crisis-development?fbclid=IwAR2-QCBdQIZ56iCG2gSP0JT1_iWjp0N203qzytbmN8VKgSOtoGmaWM2YKV

*Russian Covid-19 aid plane to US: Putin asked Trump if he needed help & he accepted, Kremlin spokesman says.* (31 March, 2020). Retrieved from RT: https://www.rt.com/news/484623-russia-coronavirus-aid-us/

Scott, J. (27 March, 2020). This is the human impact of COVID-19 – and how business can help. *World Economic Forum.* Retrieved from https://www.weforum.org/agenda/2020/03/this-is-the-human-impact-of-covid-19-and-how-business-can-help?fbclid=IwAR3yE2cqjwuh6tGgfkwaJ_ZMziLIHQ2Pgkqb4heDYvwz0B_u-Hq5XukH_Kk

Secon, H. & Woodward, A. (01 April, 2020). More than three-quarters of all Americans have been ordered to stay at home. This map shows which cities and states are under lockdown. *Business Insider.* Retrieved from https://www.businessinsider.com/us-map-stay-at-home-orders-lockdowns-2020-3

Sirletti, S., Follain, J., & Rotondi, (11 March, 2020). *Italy Announces $28 Billion Plan to Cushion Virus-Hit Economy.* Bloomberg, Retrieved from https://www.bloomberg.com/news/articles/2020-03-10/conte-calls-on-ecb-to-do-whatever-it-takes-against-coronavirus

Swanson, A. (29 March, 2020). White House Airlifts Medical Supplies From China in Coronavirus Fight. *New York Times.* Retrieved from https://www.nytimes.com/2020/03/29/business/economy/coronavirus-china-supplies.html

Tan, H. (March, 2020). There will be a ‘massive’ shuffling of supply chains globally after coronavirus shutdowns. *CNBC.* Retrieved from https://www.cnbc.com/2020/03/20/coronavirus-shocks-will-lead-to-massive-global-supply-chain-shuffle.html

Techakitteranun, H. (27 March, 2020). Thailand declares state of emergency to curb spread. *The Straits Times.* Retrieved from https://www.straitstimes.com/asia/se-asia/thailand-declares-state-of-emergency-to-curb-spread

Vahdat, A. (29 March, 2020). Iran Defends Its COVID-19 Response, Citing Economic Concerns. *Time.* Retrieved from https://time.com/5812126/iran-defends-covid-19-response/

van Fleet, J. (18 March, 2020). Education in the time of COVID-19. Global Partnership for Education. Retrieved from https://www.globalpartnership.org/blog/education-time-covid-19

*Vietnam announces $1.16bln stimulus package to help virus-hit businesses -state media.* (03 March, 2020). Retrieved from Reuters:

https://www.reuters.com/article/health-coronavirus-vietnam-economy/vietnam-announces-1-16bln-stimulus-package-to-help-virus-hit-businesses-state-media-idUSL4N2AW2UX

White House. (16 March, 2020). *G7 Leaders' Statement.* Retrieved from the White House: https://www.whitehouse.gov/briefings-statements/g7-leaders-statement/.

WHO. (n.d.). *Coronavirus*. Retrieved from https://www.who.int/health-topics/coronavirus.

World Bank. (30 March, 2020). *"World Bank. 2020. World Bank East Asia and Pacific Economic Update, April 2020: East Asia and Pacific in the Time of COVID-19.* (pp. 160-162). Washington, DC: World Bank. Retrieved from https://openknowledge.worldbank.org/handle/10986/33477

World Tourism Organization (UNWTO). (06 March, 2020). *COVID-19: UNWTO Calls on Tourism To Be Part of Recovery Plans.* Retrieved from https://www.unwto.org/news/covid-19-unwto-calls-on-tourism-to-be-part-of-recovery-plans

Worldometers. (01 April, 2020). *COVID-19 Coronavirus Pandemic.* Retrieved from https://www.worldometers.info/coronavirus/

Zhang, W. (02 March, 2020). Domestic Violence Cases Surge During COVID-19 Epidemic. *Sixth Tone.* Retrieved from https://www.sixthtone.com/news/1005253/domestic-violence-cases-surge-during-covid-19-epidemic

Cambodia Development Center

Cambodia Development Center (@cd.centerkh)

bodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center